**ឯកសារស្រាវជ្រាវ**

គណៈកម្មការទី២ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

# ក្រមប្រតិបត្តិ និងក្រមសីលធម៌របស់សមាជិកសភាៈ

## ការសិក្សាប្រៀបធៀបរវាងប្រទេសបារាំង អូស្ត្រាលី និងកាណាដា

អ្នកស្រាវជ្រាវៈ **អាប់ចូវិនសិន សេបាស្ទៀន**
ខែវិច្ឆិកា ឆ្នាំ២០១៣

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

**សង្ខេបអត្ថបទ**........................................................................................................ 1

**សេចក្តីផ្តើម**............................................................................................................ 3

**I-ក្រមប្រតិបត្តិ ប្រៀបធៀបនឹងក្រមសីលធម៌ ..........................................................4**

**II-ក្រមសីលធម៌ និងគោលការណ៍សីលធម៌ នៅប្រទេសបារាំង ...............................5**

១- ប្រភព និងការកកើតឡើងក្រមសីលធម៌ និងគោលការណ៍សីលធម៌ ............................ 5

២-គោលដៅនៃការបង្កើតក្រមសីលធម៌និងគោលការណ៍សីលធម៌នៅប្រទេសបារាំង ........ 7

៣- លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌សភាបារាំង .............................................. 7

៤- ការអនុវត្តក្រមសីលធម៌ ........................................................................................ 8

៥- ប្រតិបត្តិការក្រមសីលធម៌បារាំង ........................................................................... 10

៦-តើក្រមសីលធម៌អនុវត្តចំពោះសភាទាំងពីរឬទេ?........................................................ 10

៧- ទណ្ឌកម្មនៅក្នុងក្រមសីលធម៌ ............................................................................ 11

៨- បញ្ហានៅជុំវិញការអនុវត្តក្រមសីលធម៌ .................................................................. 11

**III-ប្រទេសអូស្ត្រាលី..................................................................................................13**

១- ប្រភព និងការកកើតឡើងក្រមសីលធម៌ ................................................................... 13

២-គោលដៅនៃការបង្កើតក្រមសីលធម៌នៅប្រទេសបារាំង................................................ 14

៣- លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌ ............................................................. 15

៤- ការអនុវត្តក្រមសីលធម៌ ...................................................................................... 15

៥- ប្រតិបត្តិការក្រមសីលធម៌ ..................................................................................... 16

៦-តើក្រមសីលធម៌អនុវត្តចំពោះសភាទាំងពីរឬទេ?....................................................... 17

៧- ទណ្ឌកម្មនៅក្នុងក្រមសីលធម៌ ............................................................................ 17

៨- បញ្ហានៅជុំវិញការអនុវត្តក្រមសីលធម៌ .................................................................. 18

**IV-ប្រទេសកាណាដា**........................................................................................**19**
១- ប្រភព និងការកកើតឡើងក្រុមសីលធម៌សមាជិកសភាកាណាដា................................19
២-គោលដៅនៃការបង្កើតក្រុមសីលធម៌និងគោលការណ៍សីលធម៌នៅប្រទេសកាណាដា.20
៣- លក្ខណៈពិសេសមួយចំនួននៃក្រុមសីលធម៌សភាកាណាដា......................................20
៤- ការអនុវត្តក្រុមសីលធម៌..........................................................................................21
៥- ប្រតិបត្តិការក្រុមសីលធម៌កាណាដា........................................................................22
៦-តើក្រុមសីលធម៌អនុវត្តចំពោះសភាទាំងពីររឺទេ?.......................................................23
៧- ទណ្ឌកម្មនៅក្នុងក្រុមសីលធម៌...............................................................................23
៨- បញ្ហានៅជុំវិញការអនុវត្តក្រុមសីលធម៌..................................................................23
**V-ជំហានក្នុងការបង្កើតក្រុមសីលធម៌សម្រាប់ព្រឹទ្ធសភាកម្ពុជា**...............................**24**
១- ឆន្ទៈនយោបាយ........................................................................................................25
២ការព្រមព្រៀងគ្នាលើគោលការណ៍ទូទៅ-......................................................................26
៣- ការបង្កើតវិធានដែលមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ..................................................27
៤យន្តការអនុវត្ត -..........................................................................................................29
៥ការអនុវត្ត -.................................................................................................................30
៦សេចក្តីសន្និដ្ឋាន -.........................................................................................................30
**VI- សេចក្តីសន្និដ្ឋាន**..........................................................................................**31**
**គន្ថនិទេស**...................................................................................................................31

# ខ្លឹមសារសង្ខេប

ឯកសារនេះនឹងបង្ហាញអំពីក្រមសីលធម៌សភា។ ចំណុចសំខាន់ដែលនឹងត្រូវលើកបង្ហាញគឺការសិក្សាប្រៀបធៀបអំពីបទពិសោធន៍នៃការបង្កើត និងដំណើការក្រមសីលធម៌សភាតាមរយៈការសិក្សាលើប្រទេសមួយចំនួន។ ឯកសារនេះក៏នឹងបកស្រាយផងដែរអំពី ក្រមសីលធម៌សភាដែលកំពុងប្រើប្រាស់នៅក្នុងប្រទេសកាណាដា បារាំង និងក្រមដែលកំពុងរៀបចំធ្វើឡើងនៅប្រទេសអូស្ត្រាលី ដោយពិនិត្យមើលទៅលើ ដើមកំណើតនិងវត្តមាននៃក្រមសីលធម៌ លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌ វិធីពង្រឹងការអនុវត្តក្រមសីលធម៌ ការប្រតិបត្តិក្រមសីលធម៌ វិសាលភាពអនុវត្តរបស់ក្រមសីលធម៌ចំពោះសភា ទណ្ឌកម្មដែលអាចមានចែងនៅក្នុងក្រមសីលធម៌ និងបញ្ហានានាពាក់ព័ន្ធនឹងការបង្កើតនិងដំណើការក្រមសីលធម៌។ ផ្អែកលើបទពិសោធន៍ទាំងអស់នេះ ឯកសារនេះក៏នឹងបង្ហាញលម្អិតអំពីជំហានដែលត្រូវអនុវត្តនៅក្នុងការបង្កើតក្រមសីលធម៌មួយ ដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការរបស់ព្រឹទ្ធសភាកម្ពុជា ពាក់ព័ន្ធនឹងក្រមសីលធម៌ដែលកំពុងស្ថិតក្នុងការពិចារណា។

ចំពោះមុខ ក្រមសីលធម៌គឺជាឧបករណ៍មួយដែលអាចជួយលើកកម្ពស់សេចក្តីទុកចិត្តរបស់សាធារណៈជនចំពោះសមាជិកសភា។ តាមរយៈក្រមសីលធម៌សភាដែលនឹងត្រូវលើកយកមកសិក្សាបង្ហាញថា មានមធ្យោបាយពីរដែលជួយសម្រេចនូវគោលបំណងខាងលើនេះបាន។ ទីមួយ ក្រមសីលធម៌បង្កើតនូវការណែនាំមួយអំពីឥរិយាបថដែលអាចទទួលយកបាន ដែលសមាជិកសភាមួយរូបគួរអនុវត្ត ជាពិសេសនៅក្នុងទំនាក់ទំនង នយោបាយនិងសេដ្ឋកិច្ច។ ទីពីរ មន្ត្រីឯករាជ្យមួយរូបត្រូវបានតែងតាំង[1] ដែលមានមុខងារសំខាន់បំផុតគឺស៊ើបអង្កេត និងផ្សព្វផ្សាយជាសាធារណៈអំពីផលប្រយោជន៍សេដ្ឋកិច្ច និងទំនាក់ទំនងសេដ្ឋកិច្ចរបស់សមាជិកសភា ក៏ដូចជាអំពីករណីជម្លោះផលប្រយោជន៍ និងករណីល្មើសណាមួយចំពោះក្រមសីលធម៌ផងដែរ។ ដូច្នេះហើយគេអាចនិយាយបានថា ឧបសគ្គមួយដែលរារាំងមិនឲ្យ សមាជិកសភាបំពានក្រមសីលធម៌ គឺ មតិរបស់សាធារណៈជនមកលើពួកគេ ពោលគឺមិនមែនទណ្ឌកម្មដែលកំណត់នៅក្នុងក្រមនោះទេ។

[1]លើកលែងករណីព្រឹទ្ធសភាបារាំង ដែលទុកឲ្យគណៈកម្មាធិការផ្ទៃក្នុងជាអ្នកអនុវត្តក្រមសីលធម៌ទៅវិញ។

លទ្ធផលដែលឯកសារស្រាវជ្រាវនេះរកឃើញថាជាកត្តាចាំបាច់បំផុត សម្រាប់ការកសាងក្រមសីលធម៌មួយនៅក្នុងសភាកម្ពុជាគឺ ការគាំទ្រផ្នែកនយោបាយដ៏ទូលំទូលាយ និងការប្រឹក្សាយោបល់ដើម្បីឲ្យមានការគាំទ្របៀបនេះ។ មានហេតុផលពីរយ៉ាង ដែលបញ្ជាក់ថាកត្តានេះមានសារៈសំខាន់ជាពិសេស។ ទីមួយ ដោយសារថាសមាជិកសភាគ្រប់រូប ត្រូវមានការទទួលខុសត្រូវចង់ពង្រឹងការអនុវត្តក្រមសីលធម៌ស្រាប់ទៅហើយ។ ដូច្នេះជាការចាំបាច់ណាស់ដែលគណៈបក្សនយោបាយសំខាន់ៗទាំងអស់គាំទ្រការបង្កើត និង ការអនុវត្តក្រមសីលធម៌។ ទីពីរ ការប្រឹក្សាយោបល់និងការស្រាវជ្រាវមានសារៈសំខាន់ ណាស់ដើម្បីធានាឲ្យមានតុល្យភាពដ៏ល្អមួយរវាងឥរិយាបថប្រកបដោយសីលធម៌របស់ សមាជិកសភា និងការធានាថាសេរីភាពរបស់គាត់មិនមានការរឹតត្បិត ដើម្បីអាចអនុវត្ត កាតព្វកិច្ចរបស់ខ្លួនបាន ពេញលេញនិងដោយសេរីក្នុងនាមជាសមាជិកសភា។

## សេចក្តីផ្តើម

ក្រមប្រតិបត្តិគឺជាការវិវត្តថ្មីមួយនៅក្នុងកិច្ចការសភា។ បើពិនិត្យមើលនៅក្នុងប្រទេសទាំង បីដែលត្រូវសិក្សា ប្រទេសអូស្ត្រាលី ប្រទេសអូស្ត្រាលីកំពុងរៀបចំអោយមានក្រមប្រតិបត្តិមួយ ប្រទេសកាណាដា បានបញ្ចប់រួចរាល់នូវការតាក់តែង ក្រមប្រតិបត្តិរបស់គេតាំងពីឆ្នាំ២០០៥មក ចំណែកឯប្រទេសបារាំង ទើបនឹងបង្កើតអោយមានក្រមសីលធម៌សម្រាប់សមាជិករដ្ឋសភានៅឆ្នាំ ២០១១ និង គោលការណ៍សីលធម៌ **(Ethics Principles)** សម្រាប់សមាជិកព្រឹទ្ធសភាកាលពីឆ្នាំ ២០០៩មក។

គេតែងនិយាយពីក្រមប្រតិបត្តិ **(Code of Conduct)** ដោយសំដៅលើក្រមសីលធម៌ **(Codes of Ethics)** ដែលអាចបែងចែកជាពីរប្រភេទៈ ទី១ គឺមានលក្ខណៈជាបញ្ញត្តិបង្ខំឲ្យអនុវត្ត និងទី២ គឺមានលក្ខណៈជម្រុញទឹកចិត្តឲ្យអនុវត្ត។ ប្រទេសកាណាដាអនុម័តយកគំរូដែលមានលក្ខណៈជាបញ្ញត្តិចាប់បង្ខំឲ្យអនុវត្ត ដោយបរិយាយយ៉ាងលំអិតអំពីសកម្មភាព និងទំនាក់ទំនងទាំងឡាយណាដែលមិនត្រូវបានអនុញ្ញាត្តិអោយធ្វើ។ ទម្រង់នេះខុសពីវិធីសាស្ត្រជម្រុញទឹកចិត្តឲ្យអនុវត្តដែលប្រកាន់យកដោយប្រទេសបារាំង(និងបច្ចុប្បន្នកំពុងស្នើឡើងនៅអូស្ត្រាលី) ដែលយោងតាមវិធីសាស្ត្រនេះ ក្រមប្រតិបត្តិរឺក្រមសីលធម៌តំណាងអោយគុណតម្លៃផ្សេងៗ ដែលសមាជិកសភាគួរតែប្រតិបត្តិតាម។ គំរូបែបនេះមិនមានបំណងរៀបរាប់ដោយលំអិតអំពីអ្វីដែលមិនគួរធ្វើនោះឡើយ ប៉ុន្តែផ្ទុយទៅវិញគឺអនុញ្ញាត្តឲ្យស្ថាប័នមានសមត្ថកិច្ចរបស់សភា ដែលពាក់ព័ន្ធកំណត់អ្វីដែលមិនគួរឲ្យធ្វើទៅតាមករណីជាក់ស្តែងនិមួយៗ។

យើងគួរកត់សំគាល់ថាពាក្យ**ក្រមប្រតិបត្តិ** និង**ក្រមសីលធម៌** គ្រាន់តែជាផ្នែកមួយនៃបទបញ្ញត្តិផ្សេងៗដែលគ្រប់គ្រងលើឥរិយាបទរបស់សមាជិកសភាប៉ុណ្ណោះ។ ចំណុចនេះគឺកំពុង អនុវត្តនៅប្រទេសបារាំង និងប្រទេសកាណាដា ដែលនៅក្នុងប្រទេសទាំងពីរនេះ ច្បាប់រដ្ឋបាល រដ្ឋប្បវេណី និងព្រហ្មទណ្ឌផ្សេងៗរួមទាំងបទបញ្ជាទាំងឡាយរបស់សភាក៏បានចែងផងដែរ អំពីសកម្មភាពរបស់សមាជិកសភា។ នៅប្រទេសអូស្ត្រាលី លិខិតូបករណ៍ដូចនេះគឺលិខិតូបករណ៍ សំខាន់តែមួយគត់ក្នុងការធ្វើនិយ័តភាពលើសកម្មភាពរបស់សមាជិកសភា ហើយសភាអូស្ត្រាលីពុំទាន់មានក្រមសីលធម៌នៅឡើយទេ។

ដូច្នេះដោយសារតែរាល់សកម្មភាពខុសច្បាប់ និងអំពើពុករលួយទាំងឡាយណាមានចែងរួចហើយក្នុងច្បាប់ និងបទបញ្ជាជាធរមាននោះ ការបង្កើត**ក្រមប្រតិបត្តិ** និង**ក្រមសីលធម៌** តែងតែត្រូវបានគេចាត់ទុកថាជាយន្តការ សម្រាប់លើកកំពស់ការទុកចិត្តពីសាធារណៈជនចំពោះសមាជិកសភាហើយក៏ជាម៉ែត្រមួយសម្រាប់សមាជិកសភាដើម្បីវាស់ស្ទង់សកម្មភាពរបស់ខ្លួនចំពោះសា

ធារណៈជនផងដែរ។ ជាចុងក្រោយ **ក្រមប្រតិបត្តិរឺក្រមសីលធម៌** បង្ហាញនូវតម្លាភាព ទាក់ទងនឹងផលប្រយោជន៍ដែលសមាជិកសភាមាន និងទំនាក់ទំនងហិរញ្ញវត្ថុផ្សេងៗរបស់ខ្លួន។តម្លាភាពនេះរួមផ្សំនឹងការដាក់សំពាធពីសាធារណៈជនទៅលើសមាជិកសភានោះ អាចជម្រុញពួកគេឲ្យធ្វើអ្វីក្នុងនាមជាអ្នកបម្រើអោយផលប្រយោជន៍សាធារណៈច្រើនជាងផលប្រយោជន៍ ឯកជនផ្ទាល់ខ្លួនរបស់គាត់។

ឯកសារនេះនឹងសិក្សាអំពីក្រមប្រតិបត្តិ/ក្រមសីលធម៌ និងការអនុវត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជាលើផ្នែកធំៗចំនួន៥។ ផ្នែកទី១ និយាយជាសង្ខេបពី**ក្រមប្រតិបត្តិ** និង**ក្រមសីលធម៌** ។ ផ្នែកទី២ ទី៣ និងទី៤ នឹងនិយាយអំពីលក្ខន្តិកៈ និងធម្មជាតិនៃក្រមប្រតិបត្តិ/ក្រមសីលធម៌ របស់សភានៃប្រទេសអូស្ត្រាលី កាណាដា និងបារាំង។ ជាចុងក្រោយ ផ្នែកទី៥ នឹងពិភាក្សាអំពីជំហានដែលអាចប្រកាន់យកសម្រាប់បង្កើតក្រមសីលធម៌មួយសម្រាប់សមាជិក ព្រឹទ្ធសភាកម្ពុជា។

## I- ក្រមប្រតិបត្តិ ប្រៀបធៀបនឹងក្រមសីលធម៌

គេតែងតែប្រើពាក្យ**ក្រមប្រតិបត្តិ** និង**ក្រមសីលធម៌**ជំនួសអោយគ្នាទៅវិញទៅមក ហើយពេលខ្លះគេពិបាកនឹងបែងចែកពាក្យទាំងពីរនេះណាស់។ គេពិបាកពន្យល់អោយបានច្បាស់លាស់នូវអ្វីទៅដែលហៅថា**ក្រមសីលធម៌** ហើយអ្នកអនុវត្តផ្សេងៗពិបាកនឹងកំណត់និយមន័យឲ្យបានច្បាស់ណាស់។ ពាក្យ**ក្រមសីលធម៌**គេច្រើនប្រើប្រាស់នៅក្នុងវិស័យមួយចំនួនដូចជាវិស័យវេជ្ជសាស្ត្រ និងច្បាប់ជាដើម។ ពាក្យក្រមសីលធម៌ និងក្រមប្រតិបត្តិច្រើនប្រើជំនួសឲ្យគ្នាទៅវិញទៅមកហើយពាក្យទាំងពីរនេះតែងតែត្រូវបានគេពន្យល់ថាជា*«សំណុំនៃបន្ទាត់នាំផ្លូវទាំងឡាយដែលមានគោលបំណងញ៉ាំងអោយមានរឺដាក់ចេញនូវឥរិយាបទត្រូវប្រតិបត្តិតាម រឺជាសីលធម៌សម្រាប់ក្រុមជាក់លាក់ណាមួយ»*[2]។

ទោះជាយ៉ាងនេះក្តី ក៏មានមតិខ្លះលើកឡើងពីភាពខុសប្លែកគ្នាបន្តិចរវាងពាក្យទាំងពីរនេះ ដោយផ្អែកលើកំរឹតនិងភាពជាក់លាក់នៃអត្ថន័យរបស់វា៖ *«ឯកសារទូទៅទូលំទូលាយហៅថាក្រមសីលធម៌ ចំណែកឯឯកសារជាក់លាក់ហៅថាក្រមប្រតិបត្តិ»*[3]។ តាមន័យនេះ **ក្រមសីលធម៌** អាចអោយនិយមន័យបានថាជា *«បណ្តុំនៃគោលការណ៍សីលធម៌ អ្វីដែលគួរតែប្រតិបត្តិតាមដើម្បី*

[2] King Prajadhipok's Institute, *Codes of conduct for parliamentarians*, February 2008, p. 7.

[3] ឯកសារយោងដូចមុន។

*ទៅរកភាពឥតខ្ចោះ វីជាតំលៃនៃអង្គការណាមួយ»*[4] ចំណែកឯ**ក្រមប្រតិបត្តិ** គឺ*«បណ្តុំនៃបទដ្ឋានរឺជាស្តង់ដារនៃអាកប្បកិរិយាដែលចាក់រឹសទៅក្នុងមុខងារនៃអង្គការដែលត្រូវអនុវត្ត។បទដ្ឋានរឺស្តង់ដារទាំងនោះតែងតែជាក់លាក់ជាងក្រមសីលធម៌ នៅក្នុងអ្វីដែល ត្រូវបញ្ញត្តិរឺហាមឃាត់»*[5]។ ជាផលវិបាកទាញចេញពីនិយមន័យនេះ ក្រមសីលធម៌ដាក់ចេញគោលការណ៍ទូទៅដែលជាធម្មតាទូលំទូលាយពាក់ព័ន្ធនឹងការដាក់ចេញបញ្ញត្តិរឺការហាមឃាត់ និងតែងតែមិនមានយន្តការសម្រាប់អនុវត្តទេ[6] ចំណែកឯក្រមប្រតិបត្តិតែងតែមាននូវសេចក្តីថ្លែងការណ៍កំណត់អ្វីត្រូវប្រព្រឹត្តិតាម និងការហាមឃាត់ផ្សេងៗ ដោយអមមកជាមួយនូវទណ្ឌកម្មផង[7]។ ទោះមានភាពខុសប្លែកគ្នាយ៉ាងណាក៏ដោយក៏គោលដៅរបស់ក្រមនេះមានលក្ខណៈដូចគ្នា គឺលើកកំពស់គោលការណ៍ទាំងឡាយដើម្បីបង្ហាញផ្លូវឥរិយាបទសមាជិកសភាក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន។

## II- ក្រមសីលធម៌ និងគោលការណ៍សីលធម៌ នៅប្រទេសបារាំង

ប្រទេសបារាំងប្រកាន់យករបបសភាពីរជាន់ដោយមានរដ្ឋសភាជាសភាជាន់ទាប និងព្រឹទ្ធសភាជាសភាជាន់ខ្ពស់។ រដ្ឋសភាតំណាងអោយប្រជាជនបារាំងទាំងមូលចំណែក ឯព្រឹទ្ធសភាតំណាងអោយសមូហភាពដែនដី **(Collectivités territoriales)** របស់បារាំង[8]។

### ១- ប្រភព និងការកកើតឡើងក្រមសីលធម៌ និងគោលការណ៍សីលធម៌

រហូតមកដល់រយៈពេលថ្មីៗនេះ ប្រទេសបារាំងពុំមានបណ្តុំនៃច្បាប់រឺក្រមសីលធម៌ កំណត់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកសភាពាក់ព័ន្ធនឹងការប្រតិបត្តិមុខងាររបស់ខ្លួននោះទេ។ សិទ្ធិនិងកាតព្វកិច្ចរបស់គាត់មានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់អង្គការ ច្បាប់និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និង/រឺរដ្ឋសភា។

---

[4] ឯកសារយោងដូចមុន។

[5] ឯកសារយោងដូចមុន ទំព័រទី៨។

[6] **Commission on Government. Commission on Government, Report No 3, Perth, Western Australia, 1996,** ទំព័រ **148**។

[7] **King Prajadhipok's Institute,** ***Codes of conduct for parliamentarians*****, February 2008,** ទំព័រទី **7**។

[8] សមូហភាពដែនដីរួមមានរ៉េស៊ុង**(Régions)**ដេប៉ាតឺម៉ង់**(Départements)** និងកុម្មីន **(Communes)**រួមទាំងសមូហភាពឯនាយសមុទ្រផងដែរ **(Collectivités d'outre mer)**។

រដ្ឋធម្មនុញ្ញបារាំងក៏បានចែងផងដែរថា៖ *«ពុំមានសមាជិក(សភា)ណាម្នាក់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយមានអណត្តិអាជ្ញាបញ្ជាបានឡើយ»* (មាត្រា២៧-១)[9]។ បញ្ញត្តិនេះមានន័យថាសមាជិកសភាតំណាងអោយប្រជាជាតិទាំងមូល ហើយមិនតំណាងអោយផលប្រយោជន៍មូលដ្ឋានរឺបុគ្គលណាមួយជាក់លាក់ឡើយ។

ក្រមព្រហ្មទណ្ឌក៏បញ្ញត្តិជាពិសេសលើបទល្មើសពុករលួយ[10]ក៏នឹងត្រូវយកទៅអនុវត្តចំពោះសមាជិកសភាផងដែរ(រួមទាំងមន្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង)[11]។

ច្បាប់នៅឆ្នាំ១៩៨៨មួយ[12]គឺជាទី១ដែលកំណត់ឲ្យមានការបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់មន្ត្រីរដ្ឋាភិបាលក្នុងនោះមានសមាជិកសភា ប៉ុន្តែពុំសូវទទួលបានជោគជ័យប៉ុន្មានទេដោយសារច្បាប់នេះពុំមានសុពលភាពអនុវត្តលើញាតិជិតស្និទ្ធរបស់សភាទេ ហើយម្យ៉ាងទៀតច្បាប់នេះពុំបានកំណត់ទណ្ឌកម្មចំពោះករណីល្មើសនោះទេ។

បន្ថែមពីនេះទៀត បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា[13]បញ្ញត្តិពីកាតព្វកិច្ចរបស់សមាជិកព្រឹទ្ធសភាដែលត្រូវតែមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការ (មាត្រា១៥-១នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។ ការមិនគោរពតាមអាចនាំឲ្យមានទណ្ឌកម្មផ្សេងៗដាក់ចេញដោយប្រធានព្រឹទ្ធសភាតាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍(មាត្រា១៥-៣នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។ទណ្ឌកម្មសម្រាប់សមាជិកព្រឹទ្ធសភាអវត្តមានក្នុងកិច្ចប្រជុំគណៈកម្មការចំនួនបីលើក គឺការបណ្តេញចេញពីគណៈកម្មការដោយកាត់ប្រាក់បៀវត្ស៥0% អនុវត្តរហូតដល់សម័យប្រជុំបន្ទាប់ទៀត(មាត្រា១៥-៣នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។ បញ្ញត្តិដូចគ្នានេះដែរក៏មានចែងនៅក្នុងមាត្រា៤២នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាផងដែរ[14]ដែលចែងថា*«វត្តមាននៅក្នុងកិច្ចប្រជុំគណៈកម្មការត្រូវតែមានខានមិនបាន»* និងបញ្ញត្តិកាត់ប្រាក់បៀវត្សប្រចាំខែ២៥%ចំពោះអវត្តមានម្តងៗ។

បទបញ្ជាផ្ទៃក្នុងសភាទាំងពីរក៏បានចែងពីទណ្ឌកម្មវិន័យផ្សេងៗចំពោះឥរិយាបទទាំងឡាយណាដែលមិនសមរម្យក្នុងកិច្ចប្រជុំពេញអង្គ ដូចជា(ដើម្បីធានាបាននូវភាពម៉ឺងម៉ាត់)ការក្រើនរំលឹកការក្រើនរំលឹកដោយមានចុះក្នុងកំណត់ហេតុ ពិន័យ និងពិន័យដោយបណ្តេញចេញជាបណ្តោះ

---

[9] សំរាប់ការបកប្រែជាភាសារអង់គ្លេសផ្លូវការសូមចូលអាន **http://www.conseil-constitutionnel.fr/conseil-constitutionnel/english/constitution/constitution-of-4-october-1958.25742.html**

[10] សូមអានជាឧទាហរណ៍មាត្រា៤៣២-១១ នៃក្រមព្រហ្មទណ្ឌបារាំង។

[11] ***Parliamentary Code of conduct in Europe, An overview,*** **Dick Toomstra, ECPRD, European Parliament, 2001.**

[12] Law No. 88-227 of 11 March 1988 on Financial Transparency in Political Life *(Loi relative à la transparence financière de la vie politique),* available at : *http://www.legifrance.gouv.fr/affichTexte.do?cidTexte=JORFTEXT000000321646&fastPos=1&categorieLien=cid&oldAction=rechTexte* (French only)

[13] អាចរកបានតាមគេហទំព័រ **http://www.senat.fr/reglement/reglement_mono.html#toc40**

[14] អាចរកបាននៅក្នុងគេហទំព័រ **http://www.assemblee-nationale.fr/connaissance/reglement.asp#P718_60974**

អាសន្នពីអង្គប្រជុំជាដើម[15] (មាត្រា៩២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង មាត្រា៧០នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា)។ ឥរិយាបទមិនសមរម្យមានដូចជា*«ការវាយប្រហារលើ បុគ្គល រឺការរំខានណាមួយដល់សណ្តាប់ធ្នាប់សាធារណៈ»*(មាត្រា៩០-១នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា) និង*«ការយាយីនាំឲ្យអាក់ខានរឺប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងការធ្វើអត្ថាធិប្បាយជាបុគ្គលណាមួយរឺការជេរប្រមាថ ការញុះញង់ រឺការគម្រាមកំហែងណាមួយ»* (មាត្រា៧១-២ និងមាត្រា៧១-៥ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា)។

## ២-គោលដៅនៃការបង្កើតក្រមសីលធម៌និងគោលការណ៍សីលធម៌នៅប្រទេសបារាំង

មានកត្តាមួយចំនួនដូចជាការនិយាយមិនល្អពីប្រព័ន្ធឃោសនា រូបភាពមិនល្អរបស់សមាជិកសភា ចំនួនសមាជិកសភាចូលរួមប្រជុំតិចតួច និងការលំបាកផ្នែកសេដ្ឋកិច្ចរបស់ប្រជាជនបារាំងរួមចំណែកបង្ហាញអោយឃើញថាមានភាពចាំបាច់ត្រូវបង្កើតឲ្យមានក្រមសីលធម៌មួយឡើង[16]។ ចំណុចដូចបានបង្ហាញខាងលើនាំអោយសភាទាំងពីរអនុម័តនូវក្រមសីលធម៌ និងពង្រឹងបញ្ញត្តិសីលធម៌មួយចំនួនសម្រាប់សមាជិកសភា។

## ៣- លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌សភាបារាំង

សភាទាំងពីររបស់បារាំងជ្រើសរើសវិធីសាស្ត្រផ្សេងៗពីគ្នា។ តាមរយៈសេចក្តីសម្រេចរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១១[17] រដ្ឋសភាបានអនុម័តយកនូវក្របខ័ណ្ឌជាទូទៅមួយដើម្បីប្រយុទ្ធប្រឆាំងនឹងជំលោះផលប្រយោជន៍ ដែលរួមមាន៖

ក- ក្រមសីលធម៌ដែលមាន៦ចំណុច[18]៖

- ផលប្រយោជន៍ទូទៅ **(Intérêt général)**

---

[15] **Code de conduite et régime parlementaire en France, available at : http://recueil.apf-francophonie.org/spip.php?article16 (ទាញយកនៅថ្ងៃទី 17 ខែតុលា ឆ្នាំ2013).**

[16] **Marc Deschamps,*Quand la déontologie fait son entrée officielle à l'Assemblée nationale...des questions juridiques et institutionnelles surgissent*** អាចរកបាននៅក្នុងគេហទំព័រ **http://hp.gredeg.cnrs.fr/Marc_Deschamps/Pdf/AN.pdf (Retrieved on 17 October 2013).**

[17] អាចរកបាននៅក្នុងគេហទំព័រ **http://www.assemblee-nationale.fr/qui/bureau_deontologie.asp**

[18] អាចរកបាននៅក្នុងគេហទំព័រ **http://www.assemblee-nationale.fr/qui/code_deontologie.asp**

- ឯករាជ្យ **(Indépendance)**
- វត្ថុវិស័យភាព **(Objectivité)**
- ការទទួលខុសត្រូវ **(Responsabilité)**
- សេចក្តីទៀងត្រង់ **(Probité)**
- ភាពជាគំរូ **(Exemplarité)**។

ខ-ការប្រកាសខានមិនបានរបស់សមាជិកសភានូវផលប្រយោជន៍ហិរញ្ញវត្ថុ រឺទ្រព្យសម្បត្តិផ្សេងៗរបស់ខ្លួន ក៏ដូចជាផលប្រយោជនិរបស់ស្វាមី/ភរិយា និងសាច់ញាតិរបស់ខ្លួនដែលអាចនាំឲ្យមានជំលោះផលប្រយោជន៍ក្នុងពេលអនុវត្តមុខងាររឺអណត្តិរបស់ខ្លួន[19]។

បន្ទាប់មកសមាជិកសភាត្រូវតែប្រកាស ៖

- ការកែសម្រួលណាមួយទាក់ទងនឹងការប្រកាសផលប្រយោជន៍
- អំណោយ រឺវត្ថុអនុស្សាវរីយ៍ដែលមានចំនួនទឹកប្រាក់លើសពី១៥០អឺរ៉ូ
- ការធ្វើដំណើរ ឧបត្ថម្ភដោយបុគ្គលរឺអង្គការណាមួយ។

គ- ការតែងតាំងអោយមាន**អ្នកឃ្លាំមើលក្រមសីលធម៌ឯករាជ្យម្នាក់ (Déontologue)**[20]។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា **(Bureau)** បានសម្រេចមុននេះបន្តិចនៅថ្ងៃទី២៥ ខែវិច្ឆិកាឆ្នាំ២០០៩(សេចក្តីសម្រេចគណៈកម្មការអចិន្ត្រៃយ៍ឆ្នាំ២០០៩)[21]បង្កើតឲ្យមានគណៈកម្មការក្រមសីលធម៌របស់ព្រឹទ្ធសភាមួយឡើង។

## ៤- ការអនុវត្តក្រមសីលធម៌

ព្រឹទ្ធសភាជ្រើសរើសយកយន្តការផ្ទៃក្នុងដើម្បីធានាការអនុវត្តគោលការណ៍ក្រមសីលធម៌។ ក្នុងន័យនេះ ព្រឹទ្ធសភាបានបង្កើតគណៈកម្មាធិការក្រមសីលធម៌មួយដែលរួមផ្សំសមាសភាពទៅដោយសមាជិកសភាមកពីគណៈបក្សនយោបាយផ្សេងៗគ្នា។"*គណៈកម្មាធិការក្រមសីលធម៌មួយដែលមានសមាសភាពសមាមាត្រទៅនឹងក្រុមនយោបាយនឹងត្រូវបង្កើតឡើង ដើម្បីជួយកិច្ចការប្រធាននិងគណៈកម្មាធិការអចិន្ត្រៃយ៍»* (មាត្រា១-១នៃសេចក្តីសម្រេចគណៈកម្មការអចិន្ត្រៃឆ្នាំ២០០៩)។ នៅពេលបង្កើតឡើងហើយ សមាជិកគណៈកម្មាធិការនេះនឹងបោះឆ្នោតជ្រើសរើស

---

[19] មាត្រា៩នៃសេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ឆ្នាំ២០១១ និងមាត្រា៥នៃក្រមសីលធម៌។

[20] អាចរកបាននៅក្នុងគេហទំព័រ**http://www.assemblee-nationale.fr/qui/deontologie.asp**

[21] Available at http://www.senat.fr/fileadmin/Fichiers/Images/role/arrete_bureau_creation_comite_deontologie.pdf (French only)

ប្រធាន និងអនុប្រធានរបស់ខ្លួន (មាត្រា ១-២)[22]។ សមាសភាពគណៈកម្មាធិការនេះនឹងត្រូវសើរើរៀងរាល់បីឆ្នាំម្តងទៅតាមអណត្តិរបស់ព្រឹទ្ធសភា ហើយសមាជិកម្នាក់មិនអាចត្រូវបានជ្រើសរើសលើសពីពីរដងឡើយ(មាត្រា៣)។សមាជិកគណៈកម្មាធិការនេះមិនទទួលប្រាក់បៀវត្សរ៍បុព្វសិទ្ធិណាមួយក្រៅពីប្រាក់បៀវត្សរ៍បុព្វសិទ្ធិក្នុងតំណែងជាសមាជិកព្រឹទ្ធសភានោះទេ (មាត្រា ៤)។

គណៈកម្មាធិការក្រមសីលធម៌គឺជាអង្គការពិគ្រោះយោបល់ ដែលផ្តល់យោបល់តាមសំណើរបស់ប្រធានព្រឹទ្ធសភ រឺរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ គណៈកម្មាធិការនេះមិនអាចផ្តល់យោបល់តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួនបានទេ។ ដែនសមត្ថកិច្ចរបស់គណៈកម្មាធិការនេះត្រូវកំណត់ត្រឹម*«បញ្ហាសីលធម៌ពាក់ព័ន្ធនឹងលក្ខខ័ណ្ឌនៃការអនុវត្តអណត្តិរបស់សមាជិកព្រឹទ្ធសភា និងមុខងាររបស់ខ្លួន»* (មាត្រា២)[23]។ យើងអាចនិយាយបានថាគណៈកម្មាធិការក្រមសីលធម៌គឺជាអង្គការពិគ្រោះយោបល់ ដោយពុំមានអំណាចអ្វីដើម្បីដាក់ទណ្ឌកម្មប្រឆាំងនឹងការបំពានសីលធម៌ឡើយ។

ចំពោះរដ្ឋសភាវិញ សេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ចុះឆ្នាំ២០១១បានបង្កើតឲ្យមាននូវ**អ្នកឃ្លាំមើលក្រមសីលធម៌ម្នាក់**។ អ្នកឃ្លាំមើលក្រមសីលធម៌នេះគឺជាបុគ្គលឯករាជ្យតែងតាំងដោយសំឡេង៣/៥នៃសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ទាំងមូល បន្ទាប់ពីមានការតែងតាំងដោយប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមានការយល់ព្រមយ៉ាងហោចណាស់ពីប្រធានក្រុមនយោបាយបក្សប្រឆាំងម្នាក់[24]។ អ្នកឃ្លាំមើលក្រមសីលធម៌ទទួលបន្ទុកទី១ ទទួលនិងផ្តល់យោបល់ពីសមាជិកសភាលើការប្រកាសផលប្រយោជនិរបស់ខ្លួន ទី២ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តក្រមសីលធម៌ ដោយមានបញ្ចូលនូវអនុសាសនិផងដែរ។

អ្នកឃ្លាំមើលក្រមសីលធម៌ក៏ទទួលបន្ទុកក្នុងការជូនព័ត៌មានទៅអោយប្រធានរដ្ឋសភា និងសមាជិកសភាដែលពាក់ព័ន្ធទាក់ទងនឹងការបំពានក្រមសីលធម៌(មាត្រា៥ នៃសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍)។ ប្រសិនបើសមាជិករដ្ឋសភានោះមិនយល់ស្របនឹងវិធានការណ៍នោះទេ គាត់អាចប្តឹងទៅប្រធានរដ្ឋសភាបាន ហើយប្រធានសភានឹងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍

---

[22] បច្ចុប្បន្ននេះគណៈកម្មាធិការក្រមសីលធម៌មានប្រធានរបស់ខ្លួនគឺលោកជំទាវ**Cathérine TASCA** (ក្រុម សង្គមនិយម**)** អនុប្រធានឯកឧត្តម **Jean-Léon DUPONT** (ក្រុម **UC-Union des Démocrateset Indépendants)** និងមានសមាជិក៤រូបគឺឯកឧត្តម **Nicolas ALFONSI** (ក្រុម **RDS-Rassemblement Démocratique et Social européen)** លោកជំទាវ**Eliane ASSASSI** (ក្រុមកុម្មុយនីស្ត**)** ឯកឧត្តម **René GARREC** (ក្រុម**UMP)** និង លោក ជំទាវ **Hélène LIPIETZ** (ក្រុមបរិដ្ឋាននិយម)។

[23] មាត្រា២ នៃសេចក្តីសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

[24]សព្វថ្ងៃនេះអ្នកឃ្លាំមើលក្រមសីលធម៌គឺលោកស្រី**Noël LENOIR**ដែលជាអតីតមន្ត្រីរាជការព្រឹទ្ធសភាជាមេធាវីអតីតសមាជិកកុងសីដេតា **(Conseil d'Etat)** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងជាសាស្ត្រាចារ្យ ច្បាប់។ អាចរកមើលបាននៅក្នុងគេហទំព័រ **http://www.assemblee-nationale.fr/qui/deontologie.asp.**។

ដើម្បីពិនិត្យ។ គណៈកម្មាធិការអចិន្ត្រៃយ៍នឹងសម្រេចក្នុងរយៈពេល២ខែ។ នៅក្នុងតំណាក់កាលនេះ នីតិវិធីត្រូវធ្វើជាសំងាត់ (កថាខ័ណ្ឌ១)។ គណៈកម្មាធិការអចិន្ត្រៃយ៍អាចស្នើសុំធ្វើសវនាការសមាជិករដ្ឋសភារូបនោះបាន រឺគាត់អាចស្នើសុំឲ្យស្តាប់យោបល់របស់គណៈកម្មាធិការអចិន្ត្រៃយ៍បាន (កថាខ័ណ្ឌ២)។ ប្រសិនបើគណៈកម្មាធិការអចិន្ត្រៃយ៍ យល់ស្របនឹងយោបល់របស់អ្នកឃ្លាំមើលក្រមសីលធម៌ថាពិតជាមានការបំពានក្រមសីលធម៌ មែនសមាជិករដ្ឋសភានោះនឹងត្រូវស្នើឲ្យប្រកាន់យកវិធានការណ៍កែតម្រូវស្ថានភាពរបស់ខ្លួនឡើងវិញ (កថាខ័ណ្ឌ៣)។

ខុសពីគណៈកម្មាធិការក្រមសីលធម៌ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប្រសិនបើទទួលបានពត៌មានពីការបំពានក្រមសីលធម៌ពីអ្នកឃ្លាំមើលក្រមសីលធម៌ហើយ មានអំណាចចាត់វិធានការណ៍និងធ្វើសេចក្តីសន្និដ្ឋានប្រឆាំងនឹងសមាជិករដ្ឋសភារូបនោះបាន។

## ៥- ប្រតិបត្តិការក្រមសីលធម៌បារាំង

ក្រមសីលធម៌សមាជិករដ្ឋសភាដំណើការក្រោមការឃ្លាំមើល របស់អ្នកឃ្លាំមើលក្រមសីលធម៌ម្នាក់ដែលជាបុគ្គលឯករាជ្យ។ ចំណែកឯនៅព្រឹទ្ធសភា ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តត្រូវបានប្រគល់អោយគណៈកម្មាធិការក្រមសីលធម៌មួយ។ យន្តការរបស់រដ្ឋសភាហាក់បីដូចជាមានឯករាជ្យនិងអាចបញ្ចៀសជំលោះផលប្រយោជន៍បានល្អជាងនៅព្រឹទ្ធសភា។ ប៉ុន្តែទាំងនៅរដ្ឋសភានិងព្រឹទ្ធសភា យន្តការទាំងពីរនេះពុំមានអំណាចអនុម័ត សេចក្តីសំរេចចិត្តចាប់បង្ខំនិងទណ្ឌកម្មឡើយ។ ការអនុវត្តចំពោះការធ្វើខុសឆ្គងនៅក្នុងសភាទាំងពីរស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់សភានិមួយៗ ដែលជាអ្នកចាត់វិធានការសមស្របណាមួយ។

## ៦-តើក្រមសីលធម៌អនុវត្តចំពោះសភាទាំងពីររឺទេ?

ដូចដែលបានលើកឡើងខាងលើរួចហើយ សភាប្រទេសបារាំងនិមួយៗអនុម័តយកបទបញ្ជាផ្សេងៗពីគ្នា តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភានៅឆ្នាំ២០០៩ និងតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភានៅឆ្នាំ២០១១ ដោយមានវិធីសាស្ត្រផ្សេងៗពីគ្នាទាក់ទងនឹងរឿងក្រមសីលធម៌។ ព្រឹទ្ធសភាប្រកាន់យកយន្តការផ្ទៃក្នុង ចំណែកឯរដ្ឋសភា ជ្រើសរើសយកបុគ្គលឯករាជ្យសម្រាប់តាមដានត្រួតពិនិត្យរឿងនេះ ហើយសភាទាំងពីរផ្តល់ទៅឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍នូវអំណាចសម្រេចចិត្តនៅពេលដែលមានសមាជិកណាម្នាក់បំពារបំពាន។

## ៧- ទណ្ឌកម្មនៅក្នុងក្រមសីលធម៌

គោលការណ៍សីលធម៌ត្រូវបានចាត់ទុកថាជាគោលការណ៍នាំផ្លូវរឺជាតម្លៃសីលធម៌ ដែលគួរតែប្រកាន់យកដើម្បីជៀសវាងកុំឲ្យមានជំលោះផលប្រយោជន៍ រឺកុំឲ្យមានអំពើពុករលួយផ្សេងៗ។ ជំនួសឲ្យទណ្ឌកម្មដូចដែលកំណត់ក្នុងសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ឆ្នាំ ២០០៩ឬ២០១១ជាចុងក្រោយសមាជិកសភាត្រូវទទួលខុសត្រូវចំពោះអ្នកបោះឆ្នោតរបស់ខ្លួនតាមរយៈការធ្វើសកម្មភាពប្រកបដោយភាពត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌។ ទោះជាយ៉ាងណាក៏ដោយ ទណ្ឌកម្មដែលត្រូវបានអនុវត្តនៅក្រោមច្បាប់ទូទៅ (ឧទាហរណ៍ៈក្រមរដ្ឋបវេនីយ) (រួមទាំងការកាត់ទោសឲ្យជាប់ពន្ធនាគារ ការផាកពិន័យ និង/រឺការដកហូតសិទ្ធិ) អាចត្រូវបានយកមកអនុវត្តចំពោះករណីល្មើសលើវិធាននៃក្រមសីលធម៌របស់សភាថ្នាក់ណាមួយផងដែរ។

## ៨- បញ្ហានៅជុំវិញការអនុវត្តក្រមសីលធម៌

រឿងអាស្រូវថ្មីៗនេះ ដែលជាប់ទាក់ទងនឹងអតីតរដ្ឋមន្ត្រីក្រសួងថវិការបស់បារាំង (ដែលជាអតីតប្រធានគណៈកម្មការហិរញ្ញវត្ថុ សេដ្ឋកិច្ចនិងថវិការបស់រដ្ឋសភា)ស្តីពីគណនីធនាគារសំងាត់របស់គាត់បានបង្ហាញឲ្យឃើញនូវភាពចាំបាច់សម្រាប់ពង្រឹងគោលការណ៍ និងគោលការណ៍នាំផ្លូវផ្នែកសីលធម៌របស់សមាជិកសភា[25]។ រឿងនេះនាំអោយមានការអនុម័តនៅថ្ងៃ ទី១៧ ខែកញ្ញា ឆ្នាំ២០១៣ ដោយសភាទាំងពីរនូវសេចក្តីព្រាងច្បាប់ផ្តួចផ្តើមឡើងដោយរដ្ឋាភិបាលក្នុងគោលបំណង *«ធ្វើអោយជីវិតនយោបាយកាន់តែមានសីលធម៌ឡើង»* ដែលក្នុងនោះមានច្បាប់អង្គិនមួយត្រូវអនុវត្តចំពោះតែសមាជិកសភា[26] និងច្បាប់អង្គិនមួយទៀតអនុវត្តចំពោះមន្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចំពោះសមាជិករដ្ឋាភិបាល និងមន្ត្រីរាជការជាន់ខ្ពស់[27]។ សារព័ន្ធនៃច្បាប់ទាំងនេះមានគោលបំណងធានាអោយមានតម្លាភាពលើឥរិយាបទ សកម្មភាព និងជម្លោះ

---

[25] សំរាប់ពត៌មានលំអិតសូមអាន **http://www.lemonde.fr/politique/article/2012/12/10/si-vous-n-avez-rien-suivi-de-l-affaire-cahuzac_1804062_823448.html.**

[26] ច្បាប់លេខ២០១៣-៩០៦ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ ស្តីពី*«តម្លាភាពក្នុងរឿងជីវិតនយោបាយ»* អាចរក បាននៅក្នុងគេហទំព័រ **http://www.conseil-constitutionnel.fr/conseil-constitutionnel/francais/les-decisions/acces-par-date/decisions-depuis-1959/2013/2013-675-dc/decision-n-2013-675-dc-du-09-octobre-2013.138242.html** (ជាភាសារបារាំង)។

[27] ច្បាប់លេខ២០១៣ ៩០៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៣ ស្តីពី*«តម្លាភាពក្នុងរឿងជីវិតនយោបាយ»* អាចរក បាននៅក្នុងគេហទំព័រ **http://www.conseil-constitutionnel.fr/conseil-constitutionnel/francais/les-decisions/acces-par-date/decisions-depuis-1959/2013/2013-675-dc/decision-n-2013-675-dc-du-09-octobre-2013.138242.html** (ជាភាសារបារាំង)។

ផលប្រយោជន៍ ដែលអាចនឹងកើតមានឡើងចំពោះសមាជិកសភាមន្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង សមាជិករដ្ឋាភិបាល និងមន្ត្រីរាជការជាន់ខ្ពស់។ ច្បាប់ទាំងនោះត្រូវផ្សព្វផ្សាយ និងចូលជាធរមាននៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ បន្ទាប់ពី ការពិនិត្យមើលនិងការធ្វើវិសោធកម្មដោយក្រុមប្រឹក្សាធម្មនុញ្ញ[28]។

និយាយពីច្បាប់អង្គិនអនុវត្តចំពោះសមាជិកសភា មានបញ្ញត្តិសំខាន់ៗមួយចំនួន រួមមាន៖

- កាតព្វកិច្ចរបស់សមាជិកសភាទាំងអស់ក្នុងការប្រកាសជាសាធារណៈយ៉ាងតឹងរឹងនូវ*«សេចក្តីប្រកាសផលប្រយោជន៍»* ដែលអាចរកមើលបាននៅលើគេហទំព័រ។ ច្បាប់ក៏បញ្ញត្តិពីកាតព្វកិច្ចចំពោះជនពាក់ព័ន្ធផ្សេងទៀតដែលត្រូវប្រកាសសកម្មភាពឯកជនផ្សេងៗទោះបីសកម្មភាពទាំងនោះទទួលបានកំរៃរឺមិនទទួលបានកំរៃក៏ដោយ។ សេចក្តីប្រកាសទាំងនោះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និងសាធារណៈជនអាចរកមើលបាននៅក្នុងគេហទំព័រ ក្នុងគោលបំណងបញ្ចៀសកុំឲ្យមានជម្លោះផលប្រយោជន៍។
- ចំណុចទីពីរគឺថាច្បាប់បញ្ញត្តិពិសេសពីសកម្មភាពថ្មីៗក្នុងអណត្តិជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលអាចអំណះតទៅអនុវត្តបានតែសកម្មភាពវិទ្យាសាស្ត្រ និងអក្សរសាស្ត្រតែប៉ុណ្ណោះ។ ទីបញ្ចប់ច្បាប់បង្កើតអោយមាន *«អាជ្ញាធរជាន់ខ្ពស់ទទួលបន្ទុកកិច្ចការតម្លាភាព»*មួយ[29] **(Haute autorité de la transparence)**មួយដែលរួមផ្សំសមាសភាពទៅដោយចៅក្រមជាន់ខ្ពស់៦រូប និងឥស្សរៈជនមានសមត្ថភាព៨រូបដែលមិនមែនជាសមាជិកសភា ហើយដែលត្រូវបោះឆ្នោតជ្រើសរើសឡើងដោយរដ្ឋសភា និងព្រឹទ្ធសភាសម្រាប់អណត្តិ៦ឆ្នាំ ដោយមានអំណាចត្រួតពិនិត្យលើ ការប្រកាសផលប្រយោជន៍ ជាសាធារណៈរបស់មនុស្សដែលជាប់ពាក់ព័ន្ធ។ អាជ្ញាធរនេះក៏អាចស្នើសុំពីប្រជា ពលរដ្ឋផងដែរ[30]។

---

[28] សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ២០១៣-៦៧៥ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣ (ច្បាប់អង្គិន)។អាចរកបាន នៅក្នុងគេហទំព័រhttp://www.conseil-constitutionnel.fr/conseil-constitutionnel/francais/les-decisions/acces-par-date/decisions-depuis-1959/2013/2013-675-dc/decision-n-2013-675-dc-du-09-octobre-2013.138242.html(ជា ភាសារបារាំង)។

[29] អាចរកបាននៅក្នុងគេហទំព័រ
http://www.legifrance.gouv.fr/affichTexte.do?cidTexte=JORFTEXT000028056223&dateTexte=&categorie Lien=id ។

[30] អាចរកបាននៅក្នុងគេហទំព័រ http://www.lemonde.fr/politique/article/2013/09/17/dernier-acte-pour-les-textes-sur-la-transparence-de-la-vie-publique_3478047_823448.html ។

វិធានការណ៍ច្បាប់ទាំងនេះដែលបន្ថែមលើគោលការណ៍សីលធម៌ ដែលមានស្រាប់ហាក់បីដូចជាទទួលបានការស្វាគមន៍ជាវិជ្ជមានអំពីប្រជាជនបារាំង។ ការស្ទង់មតិមួយបានបង្ហាញថាប្រជាជនបារាំង៦នាក់ក្នុងចំណោម១០នាក់យល់ស្របនឹងវិធានការណ៍ទាំងនោះ[31]។

## III- ប្រទេសអូស្ត្រាលី

### ១- ប្រភព និងការកកើតឡើងក្រមសីលធម៌

សភាសហព័ន្ធអូស្ត្រាលីពុំមានក្រមសីលធម៌ទេក្នុងសភាទាំងពីរថ្នាក់ ទោះបីជាបញ្ហានេះត្រូវបានគិតគូរពិភាក្សាគ្នាអស់រយៈពេលជាង៣០ឆ្នាំមកហើយក្តី[32]។ ផ្ទុយទៅវិញ ការអនុវត្តសីលធម៌របស់សមាជិកសភាត្រូវធ្វើស្របទៅតាមវិធានមួយចំនួន តាមរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណីនិងក្រមព្រហ្មទណ្ឌ ច្បាប់បោះឆ្នោតសហគមន៍កុម្មុនវែល ឆ្នាំ១៩១៨ ច្បាប់បុព្វសិទ្ធិសភាឆ្នាំ១៩៨៧ បទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈសម័យ ប្រជុំដែលចែងអំពីនីតិវិធីនិងបទបញ្ជារបស់សភាសេចក្តីសម្រេចចិត្តរបស់សភា និងបញ្ជីប្រកាសផលប្រយោជន៍របស់សមាជិកសភានិងសមាជិកព្រឹទ្ធសភា។ លើសពីនេះទៅទៀត ការអនុវត្តក្រមសីលធម៌របស់រដ្ឋមន្ត្រីក៏ត្រូវអនុលោមទៅតាម *ស្តង់ដានៃសីលធម៌រដ្ឋមន្ត្រី*ដែរ[33]។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រទេសអូស្ត្រាលីកំពុងឋិតនៅក្នុងដំណាក់កាលមួយដែលស៊ីជម្រៅជាងនេះ ទាក់ទងនឹងក្រមសីលធម៌សភា។ កាលពីចុងឆ្នាំ២០១១ គណៈកម្មាធិការទទួលបន្ទុកបុព្វសិទ្ធិនិងផលប្រយោជន៍សមាជិកសភារបស់សភាតំណាងបានចងក្រង សេចក្តីព្រាងក្រមសីលធម៌មួយ ដោយធ្វើការប្រឹក្សាយោបល់ជាមួយគណៈកម្មាធិការ ទទួលបន្ទុកផលប្រយោជន៍សមាជិកព្រឹទ្ធសភារបស់ព្រឹទ្ធសភា[34]។ បន្ទាប់មកសេចក្តីព្រាង នោះត្រូវបានបញ្ជូនទៅសភាទាំងពីរដើម្បីពិភាក្សា។ ឥទ្ធិពលពីបទពិសោធន៍ របស់ប្រទេស កាណាដានិងចក្រភពអង់គ្លេសក្នុងការ

---

[31] អាចរកបាននៅក្នុងគេហទំព័រ http://www.bfmtv.com/politique/declaration-patrimoine-une-majorite-francais-sont-492204.html ។

[32] **Deirdre McKeown. 2012. *Codes of Conduct in Australian and Selected Overseas Parliaments.* Department of Parliamentary Services. Canberra. p. 5.**

[33] ***Codes of Conduct.***៣.ទំព័រ.*(ក្រមសីលធម៌)*

[34] **House of Representatives Standing Committee of Privileges and Members' Interests)**គណៈកម្មាធិការបុព្វសិទ្ធ សីលធម៌និងផលប្រយោជន៍សមាជិកសភាតំណាង(*សមាជិកព្រឹទ្ធសភា*/, **2011.*Draft Code of Conduct for Members of Parliament Discussion Paper*(*សមាជិកសភាសេចក្តីព្រាងក្រមសីលធម៌សម្រាប់*).**

ដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌សភា ធ្វើឲ្យសេចក្តី ព្រាងនេះមិនមែនជាក្រមដែលមានលក្ខណៈរឹតត្បិតខ្លាំងនិងមានវិធានលម្អិតនោះទេ ប៉ុន្តែ មានលក្ខណៈជំរុញទឹកចិត្តអនុវត្តច្រើនជាងដែលចែងអំពីសារព័ន្ធនៃគោលការណ៍មួយ ដែលសមាជិកសភាត្រូវតែគោរព និងដូចដែលកំពុងអនុវត្តនៅចក្រភពអង់គ្លេសអញ្ចឹងដែរ[35]។ ដូចជាវិធីសាស្ត្ររបស់ចក្រភពអង់គ្លេសដែរ ក្រមសីលធម៌សភារបស់អូស្ត្រាលី ត្រូវបានគេរំពឹងថានឹងត្រូវបង្កើតឡើងដោយសេចក្តីសម្រេចចិត្តរបស់សភាដែលជាសេចក្តី សម្រេចចិត្តផ្លូវការ មិនមែនដូចជាច្បាប់ធ្វើឡើងតាមការអនុម័តបោះឆ្នោតនោះទេ[36]។ គុណ សម្បត្តិនៃវិធីសាស្ត្រនេះគឺធ្វើឲ្យសេចក្តីស្នើក្រមសីលធម៌នេះមានលក្ខណៈបត់បែនគ្រប់គ្រាន់សម្រាប់អនុវត្តចំពោះបញ្ហាជាក់ស្តែងដែលកើតមាន ហើយក្រមនេះនៅតែស្ថិតនៅក្រោមយុត្តាធិការរបស់សភាដដែល មិនមែនរបស់តុលាការទេ។ ចំណុចនេះអាចជួយដល់ការធានាគោលការណ៍បែងចែកអំណាច និងអាចអនុញ្ញាតឲ្យសភាកែសម្រួលក្រម តាមការចាំបាច់[37]។

### ២-គោលដៅនៃការបង្កើតក្រមសីលធម៌នៅប្រទេសបារាំង

ជារួម គោលបំណងនៃក្រមសីលធម៌សភារបស់អូស្ត្រាលីគឺដើម្បីលើកកម្ពស់ទាំងស្តង់ដានៃឥរិយាបថសភានិងទាំងទស្សនៈសាធារណៈជនចំពោះឥរិយាបថសភា[38]។កត្តានេះបង្ហាញថាក្រមសីលធម៌នេះត្រូវរៀបចំឡើងបំពេញនូវគោលបំណងលើកកម្ពស់ស្តង់ដារនៃការយល់ឃើញរបស់សាធារណៈជន និងមួយទៀតគឺការយល់ឃើញពីស្ថាប័ន។ សម្រាប់សាធារណៈជនក្រមសីលធម៌ត្រូវតែបង្កើតស្តង់ដាមួយដែលមានការយល់ដឹងជាសាធារណៈជន ជាអ្នកវិនិច្ឆ័យឥរិយាបថដែលអាចទទួលយកបាននិងមិនអាចទទួលយក បានរបស់សមាជិកសភា ព្រមទាំងអាចធានាថាសមាជិកសភានឹងនៅតែត្រូវតែទទួលខុសត្រូវដែលជាហេតុធ្វើឲ្យទស្សនៈ របស់សាធារណៈជនចំពោះអាជីពរបស់សមាជិកសភាកាន់តែប្រសើរឡើង។ ចំពោះស្ថាប័ន ក្រមសីលធម៌អាចផ្តល់នូវមូលដ្ឋានមួយសម្រាប់ អភិវឌ្ឍស្តង់ដានៃឥរិយាបថមួយ ដែលអាចជំរុញឲ្យសមាជិកសភាអនុវត្តដើម្បីបង្កើតជាបទដ្ឋាននៃការអនុវត្តសីលធម៌មួយដែលមានសារៈប្រយោជន៍សម្រាប់រដ្ឋាភិបាលប្រជាធិបតេយ្យ[39]។

---

[35] ***Draft Code of Conduct(****សេចក្តីព្រាងក្រមសីលធម៌****)*.** ទំព័រ. ២៩៣៥-.

[36] **Ibid.** ទំព័រ. ៨៩-.

[37] **Ibid.** ទំព័រ. ២៩.៣២-

[38] ***Codes of Conduct(****ក្រមសីលធម៌សម្រាប់សមាជិកសភា****)*.** ទំព័រ.១.

[39] **Andrew Brien,** ១៩៩៨**.** ***A Code of Conduct for Parliamentarians(****ក្រមសីលធម៌សម្រាប់សមាជិកសភា****).*Department of the Parliamentary Library(**នាយកដ្ឋានបណ្ណាល័យសភា**), Canberra.** ទំព័រ. **iii.**

មូលហេតុទីបីដែលមិនសូវសំខាន់នៃការបង្កើតក្រមសីលធម៌មួយនោះ គឺដើម្បីចងក្រងសំណុំនៃវិធានដែលមានប្រភពផ្សេងៗដែលកំពុងគ្រប់គ្រងឥរិយាបថសភានាពេលបច្ចុប្បន្នឲ្យទៅជាអត្ថបទជាក់លាក់មួយ[40]។

## ៣- លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌

សេចក្តីស្នើក្រមសីលធម៌របស់អូស្ត្រាលីមានសុពលភាពអនុវត្តលើគ្រប់ទិដ្ឋភាព នៃជីវិតសាធារណៈរបស់សមាជិកសភា ប៉ុន្តែមិនអនុវត្តចំពោះជិវិតផ្ទាល់ខ្លួនពិតប្រាកដរបស់ពួកគេទេ[41]។ ចំណុចនេះមានន័យថា ក្រមសីលធម៌មិនរៀបរាប់យ៉ាងលម្អិតអំពីអ្វីដែលត្រូវធ្វើនិងអ្វីដែលមិនត្រូវធ្វើនោះទេ ប៉ុន្តែក្រមចែងអំពីស្តង់ដាមួយនៃសុច្ចរឹតភាពដែល សមាជិកសភាមានចង់អនុវត្ត។ ដូច្នេះហើយសេចក្តីស្នើក្រមនេះពុំមានដាក់បន្ទុក ថ្មីណាមួយទេ ប៉ុន្តែប្រមូលផ្តុំចងក្រងលក្ខខណ្ឌគតិយុត្តនិងទំនៀមទម្លាប់សភាដែលមាន ស្រាប់ទៅជាឯកសារមួយ។ ជារួមគោលការណ៍ចម្បងដែលមានចែងនោះគឺ ការគោរពច្បាប់ ការខិតខំប្រឹងប្រែងនិងសន្សំសំចៃ ការគោរពឥស្សរៈភាពអ្នកដទៃ សុច្ចរឹតភាព ការដម្កល់ផលប្រយោជន៍សាធារណៈខ្ពស់ជាងឯកជន[42]។

## ៤- ការអនុវត្តក្រមសីលធម៌

ដូចបង្ហាញក្នុងរូបទី១ខាងក្រោម ការព្រងឹងការអនុវត្តសេចក្តីស្នើក្រមសីលធម៌នេះពាក់ព័ន្ធនឹងការបង្កើតគណៈកម្មាធិការថ្មីមួយនៅក្នុងសភានីមួយៗ និងប្រធានគណៈកម្មាធិការរួមមួយ។ គណៈកម្មាធិការបុព្វសិទ្ធ សីលធម៌ និងផលប្រយោជន៍សមាជិកសភាតំណាងសមាជិក/ព្រឹទ្ធសភានឹងតែងតាំងស្នងការសុច្ចរឹតភាពសភាឯករាជ្យ ម្នាក់ដែលនឹងជាអ្នកទទួលពាក្យបណ្តឹងផ្តួចផ្តើមការស៊ើបអង្កេត និងត្រួតពិនិត្យ ការស៊ើបអង្កេត[43]។ បន្ទាប់មកការរកឃើញរបស់ស្នងការនេះនឹងត្រូវបានត្រួតពិនិត្យដោយ គណៈកម្មាធិការបុព្វសិទ្ធ សីលធម៌ និងផលប្រយោជន៍សមាជិកសភា

---

[40] ***Draft Code of Conduct(*សេចក្តីព្រាងក្រមសីលធម៌*).*** ទំព័រ. ២២.

[41] **Ibid.** ទំព័រ. ៧៥.

[42] **Ibid.** ទំព័រ. ៧៦.

[43] **Ibid.** ទំព័រ. ៤៥-៤៨.

តំណាងសមាជិក ព្រឹទ្ធសភា ដែលជាអ្នកផ្តល់យោបល់អំពីទណ្ឌ/ឧកម្មតាមការចាំបាច់។ ទណ្ឌកម្មទាំងនេះនឹងត្រូវអនុវត្តដោយប្រធានរបស់សភានីមួយៗ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង[44]។

## ៥- ប្រតិបត្តិការក្រមសីលធម៌

ក្រមសីលធម៌សភាអូស្ត្រាលីមិនទាន់មានទៅឡើយទេ ហើយសេចក្តីព្រាងនោះទៀតសោតក៏នៅមិនទាន់ច្បាស់លាស់ដែរ។ ប៉ុន្តែដូចបានបង្ហាញខាងលើ ក្រមសីលធម៌ នឹងត្រូវគ្រប់គ្រងដោយស្នងការសភាឯករាជ្យម្នាក់ ដែលតែងតាំងដោយគណៈកម្មាធិការសភា។ ស្នងការនេះអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងបានរឺតាមសំណើរបស់សភា។ ស្នងការនេះនឹងរាយការណ៍ពីការរកឃើញរបស់ខ្លួនទៅគណៈកម្មាធិការសភាវិញ ដែលជាអ្នកស្នើទៅប្រធានសភាដើម្បីដាក់ទណ្ឌកម្ម[45]។ នីតិវិធីនេះនឹងមានបង្ហាញនៅក្នុងគំនូស បំព្រួញដូចខាងក្រោម។ ដូចគ្នាច្រើនទៅនឹងគំរូប្រព័ន្ធសភាកាណាដា គោលបំណងនៃការ ស្នើអោយមានក្រមសីលធម៌សភាគឺលើកកម្ពស់គណៈនេយ្យភាព លប់បំបាត់ការយល់ ឃើញអវិជ្ជមានផ្សេងៗ ដែលនាំឲ្យមានការបាត់បងការទុកចិត្តពីសាធារណៈជន ដែល នាំអោយការបាត់បង់ឱកាសជាប់ឆ្នោតម្តងទៀត។

[44] Ibid.

[45] Ibid




រូបទី១៖ ប្រតិបត្តិការនៃក្រមសីលធម៌សភាអូស្រ្តាលី

### ៦-តើក្រមសីលធម៌អនុវត្តចំពោះសភាទាំងពីររឺទេ?

សេចក្តីស្នើក្រមសីលធម៌សភាអូស្រ្តាលីត្រូវបានរំពឹងថានឹងយកទៅអនុវត្តដូចគ្នាចំពោះសភាទាំងពីរ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីសភាទាំងពីរមានសិទ្ធិតាមរដ្ឋធម្មនុញ្ញក្នុងការបង្កើតលិខិតបទដ្ឋានទាក់ទងនឹងប្រតិបត្តិការនិងដំណើរការមុខងាររបស់ខ្លួនរៀងៗខ្លួន។

### ៧- ទណ្ឌកម្មនៅក្នុងក្រមសីលធម៌

សេចក្តីស្នើក្រមសីលធម៌មិនមានចែងអំពី ដោយរៀបរាប់លម្អិតទេព្រោះ...ម្មរបបទណ្ឌក“ថាភាពបត់បែនគួរតែមានដើម្បីទុកលទ្ធភាពឆ្លើយតបចំពោះ ករណីជាក់ស្តែងនីមួយៗដោយអាច

ជួយធ្វើឲ្យប្រាកដថាទណ្ឌកម្មមានលក្ខណៈសមស្របទៅនឹង កាលៈទេសៈជាក់ស្តែង"[46]។ ផ្ទុយទៅវិញ មានផ្តល់យោបល់ថា ការចែងអំពី ទណ្ឌកម្មដែលអាចយកមកអនុវត្តគួរតែត្រូវបានធ្វើដោយប្រើប្រាស់ពាក្យពេជន៍ក្នុងអត្ថន័យទូទៅដែលអនុញ្ញាតឲ្យគណៈកម្មាធិការបុព្វសិទ្ធសីលធម៌ និងផលប្រយោជន៍សមាជិកសភាតំណាងសមាជិកព្រឹទ្ធសភាអាចអនុវត្តបាន ដោយសារ/តែមានលក្ខណៈ សមស្របនឹងកាលៈទេសៈ។ ទណ្ឌកម្មដែលយកមកអនុវត្តអាចមានចាប់តាំងពីការសុំទោសរហូតដល់ការព្យួរការងារ។ បញ្ញត្តិអំពីការការពារសាក្សី និងផលប្រយោជន៍របស់ពួកគេក៏គួរតែត្រូវបានបញ្ចូលផងដែរ[47]។ ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនឹងត្រូវបញ្ជូនបន្តទៅអយ្យការសាធារណៈនិងតុលាការ[48]។

## ៨- បញ្ហានៅជុំវិញការអនុវត្តក្រមសីលធម៌

ដូចដែលបានកត់សម្គាល់ខាងលើក្រមសីលធម៌សភាអូស្ត្រាលីត្រូវបានលើកយកមកពិភាក្សា ប៉ុន្តែមិនទាន់បានអនុវត្តអស់រយៈពេលជាង៣០ឆ្នាំមកហើយ។ ចំណុចនេះក៏ព្រោះតែមិនសូវមានល្មើសធ្ងន់ធ្ងរ ហួសពីអ្វីដែលមានចែងនៅក្នុងបទបញ្ញា ផ្ទៃក្នុង *ក្រមព្រហ្មទណ្ឌ* រឺ *ច្បាប់បុព្វសិទ្ធិសភា*។ ផ្ទុយទៅវិញទស្សនៈដែលថា ការផ្លាស់ប្តូរបរិយាកាសនយោបាយ"ជាជាងការកើតមានវិបត្តិ" សីលធម៌គឺជាឫសគល់នៃសេចក្តីស្នើ ភាគច្រើននាពេលថ្មីៗនេះ សម្រាប់ការបង្កើតក្រមមួយ[49]។ ជាក់ស្តែង មូលហេតុដែលនាំឲ្យមានសេចក្តីស្នើថ្មីៗបំផុតនោះគឺដោយសារតែមានកិច្ចព្រមព្រៀងមួយ ដែលក្នុងនោះគណៈបក្សពលករដែលមានសម្លេងភាគតិចនឹងគាំទ្រការអនុម័តក្រមសីលធម៌ ជាថ្នូរនឹងការគាំទ្រត្រឡប់វិញរបស់សមាជិកឯករាជ្យមួយចំនួនដែលជាកត្តាសំខាន់សម្រាប់ការបង្កើតរដ្ឋាភិបាល[50]។ ប៉ុន្តែការអនុម័តក្រមនេះត្រូវបានរំខានដោយការបោះឆ្នោតសហព័ន្ធនិងការផ្លាស់ប្តូររដ្ឋាភិបាលជាបន្តបន្ទាប់។ សព្វថ្ងៃនេះនៅមិនច្បាស់លាស់នៅឡើយទេថារដ្ឋាភិបាលថ្មីនឹងគាំទ្រការអនុម័តក្រមនេះរឺយ៉ាងណា ។

សមាជិកសភាអូស្ត្រាលីផ្តល់ការគាំទ្រយ៉ាងទូលំទូលាយ ដល់ការអនុម័តក្រមសីលធម៌មួយសំខាន់គឺដើម្បីលើកកម្ពស់ទស្សនៈសាធារណៈជនចំពោះសភា តាមរយៈការសម្តែងការគោរព

---

[46] ***Draft Code of Conduct(****សេចក្តីព្រាងក្រមសីលធម៌****)***. ទំព័រ. ៥៩.

[47] **Ibid.**

[48] **Ibid.** *ទំព័រ. ៩.*

[49] ***Draft Code of Conduct(****សេចក្តីព្រាងក្រមសីលធម៌****)***. ទំព័រ. ២០.

[50] ***Codes of Conduct(****ក្រមសីលធម៌****)***.ទំព័រ.៥៩-.

ចំពោះសំណុំនៃវិធានដ៏គ្រប់ជ្រុងជ្រោយមួយ[51]។ មានសេចក្តី កង្វល់ចម្បងៗចំនួនបីរបស់សភាទាក់ទងនឹងក្រមសីលធម៌នេះ គឺ៖

១.សាលភាពនៃការប្តឹងដើម្បីយកចំណេញខាងនយោបាយរបស់គណៈបក្សនយោបាយ។
២ក្រមបែបនេះអាចនឹងរំខានដល់លទ្ធភាពរបស់សភាក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន. ដោយសេរីនិងពេលលេញ
៣សមាជិកសភាបិតនៅក្រោម.វិធានច្រើនណាស់ទៅហើយ ដែលចំណុចនេះធ្វើឲ្យក្រមសីលធម៌ហាក់មិនសូវចាំបាច់និងបង្កឲ្យមានភាពស្មុគស្មាញបន្ថែមទៀត[52]។

## IV- ប្រទេសកាណាដា

### ១- ប្រភព និងការកកើតឡើងក្រមសីលធម៌សមាជិកសភាកាណាដា

នៅឆ្នាំ២០០៤ សភាកាណាដាបានអនុម័តច្បាប់វិសោធនកម្មច្បាប់ ស្តីពីសភាកាណាដា (ដោយបង្កើតអោយមានស្នងការក្រមសីលធម៌ និងមន្ត្រីក្រមសីលធម៌របស់ព្រឹទ្ធសភា) ព្រមទាំងច្បាប់បន្តបន្ទាប់ផ្សេងៗទៀតផងដែរ[53]។ ចំណុចនេះបានកើតឡើងបន្ទាប់ពីការពិភាក្សានិងពិគ្រោះយោបល់អស់រយៈពេលជាង៣០ឆ្នាំរបស់សភាទាំងពីរ ស្តីពីការអនុម័តក្រមសីលធម៌សភាព្រមទាំងបានសម្របសម្រួលសភាទាំងពីរឲ្យអនុម័តក្រមដែលទាក់ទងនឹងទំនាស់ផលប្រយោជន៍ និងការបង្កើតអោយមានស្នងការក្រមសីលធម៌របស់ខ្លួនផងដែរ[54]។ វិធានការណ៍ទាំងនេះត្រូវបានកែលំអអោយកាន់តែប្រសើរឡើងដោយ*ច្បាប់ស្តីពីទំនាស់ផលប្រយោជន៍ឆ្នាំ២០០៦ច្បាប់ស្តីពីការឡបបី*ឆ្នាំ១៩៨៥ និងច្បាប់ស្តីពីគណនេយ្យភាពសហព័ន្ធឆ្នាំ២០០៦។ កាតព្វកិច្ចដែលច្បាប់ទាំងនេះដាក់ឲ្យរដ្ឋាភិបាលអនុវត្តត្រូវបានចងក្រងទៅជាឯកសារស្តីពី*រដ្ឋាភិបាលមានគណនេយ្យភាព៖ គោលការណ៍ណែនាំសម្រាប់រដ្ឋមន្ត្រីនិងសំរាប់ទេសរដ្ឋមន្ត្រី*ដែលចែងយ៉ាងក្បោះក្បាយអំពីស្តង់ដាផ្សេងៗ ដូចជាការប្រើប្រាស់គណនេយ្យចំណាយរបស់សភា ការទទួលអំណោយ និងការធ្វើ

---

[51]**Ibid.** ទំព័រ. ២៧.

[52]**Ibid.** ទំព័រ. ២៧.២៩-

[53] **Jean T. Fournier,** ២០០៩, ការលេចឡើងនៃគំរូផ្សេងៗនៃក្រមសីលធម៌សភានៃប្រទេសកាណាដា, ព្រឹត្តប័ត្រនៃច្បាប់នយោបាយ និងសភា, ភាគ២ លេខ៣ ខែឧសភា, ទីក្រុងអូតាវ៉ា, ទំព័រ៣.

[54] ដូចខាងលើ.

ដំណើរដែលទទួលបានការឧបត្ថម្ភ សេចក្តីថ្លែងការណ៍ស្តីពីអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងការដោះស្រាយជាមួយអ្នកសម្របសម្រួលដែលរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នានារបស់រដ្ឋាភិបាល ត្រូវឆ្លើយតបឲ្យបាន និងដើមកំណើតផ្នែកគតិយុត្តិនៃស្តង់ដាទាំងនេះ[55]។

## ២-គោលដៅនៃការបង្កើតក្រមសីលធម៌និងគោលការណ៍សីលធម៌នៅប្រទេសកាណាដា

ក្រមសីលធម៌របស់ប្រទេសកាណាដា មានគោលបំណងលើកកម្ពស់ការជឿជាក់របស់ សាធារណៈជនទៅលើសមាជិកសភា តាមរយៈការធានាថាសមាជិកសភាទាំងនោះឆ្លើយតបទៅនឹងស្តង់ដាក្រមសីលធម៌ខ្ពស់នានា ហើយក៏ដើម្បីលើកកម្ពស់ប្រសិទ្ធភាពរបស់សភាក្នុងនាមជាស្ថាប័នអភិបាលកិច្ចមួយ តាមរយៈការការពារភាពមិនលំអៀងនិងឥរិយាបទល្អរបស់សមាជិកសភា[56]។

## ៣- លក្ខណៈពិសេសមួយចំនួននៃក្រមសីលធម៌សភាកាណាដា

ស្នងការក្រមសីលធម៌ដំបូងរបស់ព្រឹទ្ធសភាកាណាដាបានកំណត់ជ្រុងសំខាន់ៗបួននៃរបបសីលធម៌សភាកាណាដា រួមមានៈ

១. ឯករាជ្យនៃស្នងការសីលធម៌

២. វិធានជាក់លាក់នៃឥរិយាបទសមាជិកសភា

៣. គណនេយ្យភាពរបស់អង្គនីតិបញ្ញត្តិ និង

៤. ការបញ្ជាក់ស្តីពីមុខងារការផ្តល់ប្រឹក្សានិងការបង្កា។[57]

ចំណុចខ្លឹមសារសំខាន់នៃរបបនេះគឺគណនេយ្យភាព និងតម្លាភាព។ សមាជិកសភាត្រូវប្រតិបត្តិតាមឲ្យបានច្បាស់លាស់នូវវិធានគ្រប់គ្រងនានាទៅលើសមាជិកសភា រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នានា ដើម្បីធានាថាពួកគេបំរើផលប្រយោជន៍សាធារណៈជាងផលប្រយោជន៍បុគ្គល។ ការប្រកាន់ខ្ជាប់ទៅនឹងវិធានទាំងនេះត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ ដោយស្នងការក្រមសីល

---

[55] ការិយាល័យក្រុមប្រឹក្សានយោបាយ, ២០១១, រដ្ឋាភិបាលគណនេយ្យភាពៈ គោលការណ៍ណែនាំសម្រាប់រដ្ឋមន្ត្រី, ប្រទេសកាណាដា.

[56] **Jean T. Fournier,** ២០០៩, ការវិវឌ្ឍថ្មីៗនៅក្នុងក្រមសីលធម៌សភានៃប្រទេសកាណាដា, ការសិក្សាឡើងវិញនៃសភាកាណាដា, ២០០៩, ប្រទេសកាណាដា, ទំព័រ៩.

[57] **Jean T. Fournier,** គំរូក្រមសីលធម៌សភានៃប្រទេសកាណាដា, ទំព័រ៣.

ធម៌នៃសភាទាំងពីរ ដែលធ្វើប្រតិបត្តិការដោយឯករាជ្យពីរដ្ឋាភិបាល និងមានភារៈកិច្ចធ្វើឲ្យសមាជិកសភាមានគណនីយភាពចំពោះសកម្មភាពរបស់ខ្លួន។ ជាមួយគ្នានេះដែរ ក៏មានការសង្កត់ធ្ងន់លើតួនាទីរបស់ស្នងការសីលធម៌ ក្នុងការផ្តល់ប្រឹក្សានិងការផ្តល់យោបល់ជាលក្ខណៈផ្លូវការរឺមិនផ្លូវការ ជូនសមាជិក សភាទាក់ទងនឹងការដែលខ្លួនអាចប្រព្រឹត្តល្មើសនឹងវិធាននានា មុនពេលបញ្ហាកើតមានឡើង។ ម្យ៉ាងវិញទៀត ស្នងការក៏មានសិទ្ធិក្នុងការស៊ើបអង្កេតតាមការផ្តួចផ្តើមរបស់ខ្លួនរឺតាមការស្នើសុំរបស់សមាជិកសភា រឺសមាជិករបស់រដ្ឋទៅលើឥរិយាបទរបស់សមាជិកសភា និងផ្តល់ អនុសាសន៍ផ្សេងៗសំរាប់កែលំអអោយទៅជាសកម្មភាពសមស្របសម្រាប់សភាដើម្បីដោះស្រាយករណីការប្រព្រឹត្តល្មើសនានាដែលត្រូវបានរកឃើញ[58]។

ដូចនេះ ជាលទ្ធផលដ៏ច្បាស់ចេញពីនេះគឺការកំណត់របបបោះពុម្ពផ្សាយជាប្រចាំជាសាធារណៈ នូវបញ្ជីធ្វើដំណើរដែលមានការឧបត្ថម្ភរបស់សមាជិកសភា និងការប្រមូលការចុះបញ្ជីអំណោយដែលសមាជិកសភាទទួលបាន។ លើសពីនេះ ប្រសិនបើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងលើនាំដល់ការស៊ើបអង្កេត លទ្ធផលដែលរកឃើញត្រូវផ្សព្វផ្សាយជាបន្ទាន់លើគេហទំព័រផ្លូវការ និងត្រូវធានាថាសារព័ត៌មាននិងសាធារណៈអាចទទួលបានព័ត៌មាននេះ[59]។ តម្លាភាពនេះបន្ថែមលើកម្រិតនៃការត្រួតពិនិត្យលើឥរិយាបទរបស់សមាជិកសភា[60]ជាមួយនឹងការស៊ើបអង្កេតដែលផ្តល់ភស្តុតាង ដែលនាំអោយបើកបណ្តឹងព្រហ្មទណ្ឌប្រឆាំងទៅនឹងមន្ត្រីដែលពាក់ព័ន្ធ ក្នុងករណីចាំបាច់។

### ៤- ការអនុវត្តក្រមសីលធម៌

ប្រព័ន្ធក្រមសីលធម៌សភានៃប្រទេសកាណាដាត្រូវបានត្រួតពិនិត្យនិងអនុវត្តន៍ដោយស្នងការឯករាជ្យមួយនៅក្នុងសភានីមួយៗ[61]។ នីតិវិធីនៃការតែងតាំងត្រូវបានចែងនៅក្នុងច្បាប់ស្តីពីសភានៃប្រទេសកាណាដា។ បញ្ញត្តិនេះចែងថាអគ្គអភិបាល **(Governor general)** ជាអ្នកតែងតាំងស្នងការក្រមសីលធម៌សភាជាន់ទាប និងមន្ត្រីក្រមសីលធម៌នៃសភាជាន់ខ្ពស់ ដោយពិគ្រោះយោបល់

---

[58] **Jean T. Fournier,** គំរូក្រមសីលធម៌សភានៃប្រទេសកាណាដា, ទំព័រ៣-៨.

[59] សម្រាប់ឧទាហរណ៍, សូមមើល របាយការណ៍និងឯកសារផ្សព្វផ្សាយស្តីពីស្នងការក្រមសីលធម៌នៃរដ្ឋសភាកាណាដា នៅក្នុងគេហទំព័រ **http://ciec-ccie.gc.ca/Default.aspx?pid=12&lang=en** និងការចុះឈ្មោះជាសាធារណៈ ស្តីពីមន្ត្រីក្រមសីលធម៌នៃព្រឹទ្ធសភាកាណាដា នៅក្នុងគេហទំព័រ **http://sen.parl.gc.ca/seo-cse/PublicRegistry.aspx?Lang=E&Year=2012-2013**

[60] **Mary Dawson,** ២០១៣, ច្បាប់ស្តីពីទំនាស់ផលប្រយោជន៍៖ ការសិក្សាឡើងវិញរយៈពេល៥ឆ្នាំ៖ ការដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការទទួលបានព័ត៌មាន, ភាពឯកជន និងសីលធម៌, ការិយាល័យផលប្រយោជន៍ និងស្នងការក្រមសីលធម៌, ទីក្រុងអូតាវ៉ា, ទំព័រ៦៧-៨

[61] ដូចខាងលើ ទំព័រ៣.

ជាមួយថ្នាក់ដឹកនាំនៃគណបក្សនយោបាយនីមួយៗដែលមានអសនៈនៅក្នុងសភា និងបន្ទាប់ពីបេក្ខជនភាពនេះទទួលបានការឯកភាពដោយសេចក្ដីសម្រេចចិត្តរបស់សភានោះ[62]។

## ៥- ប្រតិបត្តិការក្រមសីលធម៌កាណាដា

របបក្រមសីលធម៌នៃប្រទេសកាណាដាដំណើរការដូចតទៅ។ មន្ត្រីក្រមសីលធម៌ និងស្នងការក្រមសីលធម៌ ដែលទទួលខុសត្រូវចំពោះសភាជាន់ខ្ពស់និងសភាជាន់ទាបមានមុខនាទីជាអ្នកធានាដោយច្បាប់ស្ដីពីសភានៃប្រទេសកាណាដា ដែលថែងអំពីឯករាជ្យ និងភារៈកិច្ចចំបងៗរបស់ពួកគេ ការបកស្រាយនិងការអនុវត្តន៍ក្រមសីលធម៌។ ការទទួលខុសត្រូវរបស់អ្នកទាំងពីរនេះត្រូវអនុវត្ត ទៅតាមប្រឹក្សារបស់គណៈកម្មាធិការក្រមសីលធម៌សភារឺតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនផងដែរ។ នៅក្នុងលក្ខខ័ណ្ឌជាក់ស្ដែងភារកិច្ចទាំងនេះត្រូវបានបន្តអនុវត្តន៍ តាមរយៈមធ្យោបាយចំនួន៥៖

១.ផ្ដល់យោបល់ជាសម្ងាត់លើមូលដ្ឋានជាក់ស្ដែងជូនសមាជិកសភាដើម្បីជួយអោយសមាជិកទាំងនោះអនុវត្តទៅតាមក្រមសីលធម៌

២.ចងក្រង និងផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ប្រចាំឆ្នាំដែល ក្រមតម្រូវឲ្យមានដែលក្នុងនោះរួមមានខ្លឹមសារពិស្ដារនានា ដូចជា ប្រភពចំណូល ទ្រព្យសម្បត្តិ ការទទួលខុសត្រូវ សកម្មភាពខាងក្រៅ និងកិច្ចសន្យារដ្ឋាភិបាលផ្សេងៗ

៣.ចាប់ផ្ដើមការស៊ើបអង្កេតលើឥរិយាបទរបស់សមាជិកសភា ដែលតាមនោះ គាត់អាចកោះហៅមនុស្ស និងទទួលបានកំណត់ត្រាផ្សេងៗ។ សមាជិកសភាត្រូវតែចូលរួមសហការនៅក្នុងការស៊ើបអង្កេតនេះដែលនេះជា លក្ខខ័ណ្ឌមួយនៃការទទួលខុសត្រូវរបស់ខ្លួនចំពោះសភា។

៤.ផ្ដល់អនុសាសន៍ជាវិធានការណ៍ចាំបាច់ណាមួយសម្រាប់សមាជិកសភា ដើម្បីដោះស្រាយ ទំនាស់ផលប្រយោជន៍ជាក់ស្ដែងណាមួយដោយផ្អែកលើការប្រកាសរបស់ខ្លួន។

៥.ដាក់ជូនប្រធានសភាពិនិត្យនូវរបាយការណ៍សកម្មភាពប្រចាំឆ្នាំ ស្ដីពីការស៊ើបអង្កេតរបស់មន្ត្រីនិងស្នងការក្រមសីលធម៌ ហើយបន្ទាប់មកប្រធានសភានឹងដាក់ឯកសារនេះសម្រាប់ការត្រួតពិនិត្យជាសាធារណៈ[63]។

---

[62] ការិយាល័យមន្ត្រីក្រមសីលធម៌ព្រឹទ្ធសភា, ២០១៣, អំពីការិយាល័យ, ទីក្រុងអូតាវ៉ា http://sen.parl.gc.ca/seo-cse/eng/Office-e.html ការិយាល័យផលប្រយោជន៍និងស្នងការក្រមសីលធម៌, ២០១៣, ឯករាជ្យភាពនៃស្នងការ, ទីក្រុងអូតាវ៉ា http://ciec-ccie.gc.ca/Default.aspx?pid=75&lang=en

## ៦-តើក្រមសីលធម៌អនុវត្តចំពោះសភាទាំងពីរទេ?

ដោយសារសភាទាំងពីរមានកាតព្វកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ក្នុងការបង្កើតបទបញ្ញត្តិរៀងៗខ្លួនដោយផ្សាភ្ជាប់ទៅនឹងមុខងាររបស់ខ្លួន ដូចនេះសភាទាំងពីរមានស្នងការក្រមសីលធម៌ដាច់ដោយឡែកពីគ្នា[64]។ ផ្ទុយទៅវិញ ច្បាប់ដែលបានបញ្ជាក់ខាងលើដែលរួមមានរបបក្រមសីលធម៌សភានៃប្រទេសកាណាដា ដែលបានបង្ហាញខាងលើហើយដែលនឹងត្រូវ អនុវត្តដោយស្នងការក្រមសីលធម៌ ជាបញ្ញត្តិទូទៅហើយដែលនឹងត្រូវអនុវត្តចំពោះសភាទាំងពីរ[65]។

## ៧- ទណ្ឌកម្មនៅក្នុងក្រមសីលធម៌

បច្ចុប្បន្ន ទណ្ឌកម្មតែមួយគត់ដែលបានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមសីលធម៌នេះគឺការពិន័យជាប្រាក់ចំនួន៥០០ដុល្លារអាមេរិក សម្រាប់ការរាយការណ៍យឺតយ៉ាវទាក់ទងនឹងការធ្វើដំណើរដែលមានការឧបត្ថម្ភ ការទទួលអំណោយ ទំនាក់ទំនងជាមួយអ្នកឡបប៊ី រឺព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ដែលស្នើដោយមន្ត្រីស្នងការក្រមសីលធម៌។ ក្រៅពីនេះពុំមានទណ្ឌកម្មណាមួយផ្សេងពីនេះទេ ចំពោះការប្រព្រឹត្តល្មើសទៅនឹងច្បាប់ស្តីពីក្រមសីលធម៌នោះទេ[66] ពុំនោះទេទណ្ឌកម្មភាពអាចជាភាពខ្មាសអៀនជាសាធារណៈ[67] និងលទ្ធភាពរបស់សភាក្នុងការយល់ព្រមអនុម័តការដាក់ទណ្ឌកម្ម ប្រសិនបើយល់ថាចាំបាច់[68] ហើយតុលាការជាអ្នកធ្វើការស៊ើបអង្កេតនិងការដាក់ទណ្ឌកម្មលើអំពើល្មើសណាមួយ។

## ៨- បញ្ហានៅជុំវិញការអនុវត្តក្រមសីលធម៌

គោលការណ៍ណែនាំស្តីពីទំនាស់ផលប្រយោជន៍ផ្សេងៗ ដែលមានវិសាលភាពតិចជាងរបបក្រមសីលធម៌របស់ប្រទេសកាណាដាបច្ចុប្បន្នត្រូវបានពិភាក្សា និងផ្តើមឡើងនៅកម្រិតថ្នាក់ខេត្តក្រោយពីរឿងអាស្រូវផ្ទៃកនយោបាយវ៉តធើហ្គេត **(Watergate)** ក្នុងឆ្នាំ១៩៧៤ នៅក្នុងសហរដ្ឋអា

---

[63] **Jean T. Fournier,** គំរូក្រមសីលធម៌សភានៃប្រទេសកាណាដា, ទំព័រ៤-៥.

[64] ដូចខាងលើ ទំព័រ២.

[65] ដូចខាងលើ.

[66] ដូចខាងលើ ទំព័រ៧០.

[67] ដូចខាងលើ ទំព័រ៧០.

[68] **Jean T. Fournier,** គំរូក្រមសីលធម៌សភានៃប្រទេសកាណាដា, ទំព័រ៣-៨.

មេរិច។ ចំណែកឯ ការចាប់ផ្តើមអោយមានក្រមសីលធម៌របស់ប្រទេសកាណាដាបច្ចុប្បន្នគឺចាប់ផ្តើមចេញពីរឿង *«អាស្រូវពាក់ព័ន្ធនឹងការឧបត្ថម្ភ»* ក្នុងឆ្នាំ២០០២ដែលពាក់ព័ន្ធនឹងប្រាក់របស់រដ្ឋាភិបាលមួយចំនួនធំដែលត្រូវបានប្រើប្រាស់ខុសរឺត្រូវបានកេងបន្លំ។ ក្រោយពីបញ្ហានេះកើតឡើងគណបក្សសេរីដែលកំពុងកាន់អំណាចមានបំណង សម្រាលការខូចខាតផ្នែកនយោបាយនៃរឿងអាស្រូវខាងលើ តាមរយៈការបង្កើតអោយមាន ក្រមសីលធម៌ បច្ចុប្បន្នដ៏តឹងតែងមួយដោយមានការចូលរួមអនុវត្តន៍ពីស្នងការក្រមសីលធម៌ឯករាជ្យផងដែរ[69]។

## V- ជំហានក្នុងការបង្កើតក្រមសីលធម៌សម្រាប់ព្រឹទ្ធសភាកម្ពុជា

យើងគួរយល់ដឹងថា ក្រមសីលធម៌គឺមិនមែនជាឯកសារបច្ចេកទេសដែលត្រូវអនុវត្តទៅលើសមាជិកនៃអង្គនីតិបញ្ញត្តិ សំរាប់កែសម្រួលឥរិយាបថរបស់ពួកគាត់ដោយស្វ័យប្រវត្តិឲ្យកាន់តែប្រសើរឡើងនោះទេ។ ផ្ទុយទៅវិញ ក្រមសីលធម៌ជាបណ្តុំនៃគុណតម្លៃ និងបទដ្ឋានសមាជិកសភាស្មគ្រ័ចិត្តប្រតិបត្តិទៅតាមនោះ។

ដោយសារតែក្រមសីលធម៌ គួរតែត្រូវបានគាំទ្រ និងអនុម័តដោយមតិភាគច្រើននៃសមាជិកសភាវា វាទាមទារជាចាំបាច់ការចូលរួមដ៏ទូលំទូលាយមួយរបស់សមាជិកសភាចាប់តាំងពីតំណាក់កាលដំបូងនៃការបង្កើតក្រមសីលធម៌នេះ។ តំណាក់កាលក្រោយមកទៀតគឺដើម្បីធានាអោយមានប្រសិទ្ធិភាពកាន់តែខ្ពស់គួរតែបង្កើតអោយមានក្រុមសមាជិកសភាពិសេសមួយរឺគណៈកម្មការសភាមួយដើម្បីសិក្សាតាក់តែងលំអិតពីបញ្ញត្តិទាំងអស់នេះ។ ទោះជា យ៉ាងណាក៏ដោយ ក៏ត្រូវបន្តពិគ្រោះយោបល់ ពិនិត្យផ្ទៀងផ្ទាត់និងពិភាក្សាជាមួយសមាជិកសភាផ្សេងៗទៀតនៅក្នុងដំណើរការតាក់តែងនេះ[70]។

ដូចដែលបានកំណត់ក្នុងសៀវភៅក្បួនស្តីពីសីលធម៌ និងឥរិយាបទរបស់សមាជិកសភាដែលបានរៀបចំដោយ មូលនិធិវេសមិនធ្វើ **(Westminster Foundation)** សម្រាប់លិទ្ធិប្រជាធិបតេយ្យ និង អង្គការពិភពលោក នៃការប្រឆាំងអំពើពុករលួយរបស់សមាជិកសភា **(Global Organization of Parliamentarians Against Corruption)** មានដំណាក់កាលប្រាំនៅក្នុងដំណើរការនៃការបង្កើតរបបគ្រប់គ្រងក្រមសីលធម៌ ដែលរួមមាន៖

---

[69] ដូចខាងលើ ទំព័រ៣.

[70] សៀវភៅក្បួន, ទំព័រ. ១០.

### ១- ឆន្ទៈនយោបាយ

ជាដំបូងគេ និងជាចាំបាច់គឺឆន្ទៈនយោបាយសម្រាប់កំណែទម្រង់ត្រូវតែមាន។ ដូចដែលបានរៀបរាប់ខាងលើបញ្ញត្តិក្នុងក្រមសីលធម៌នឹងមិនត្រូវប្រតិបត្តិតាមទេប្រសិនបើមិនមានការចូលរួមដោយសមាជិកសភានោះ។

ក្នុងករណីប្រទេសកម្ពុជា គេគួរចោទសួរជាតំបូងថាតើក្រមសីលធម៌គួរតែត្រូវអនុម័តដោយព្រឹទ្ធសភា (ដោយភាគច្រើនដាច់ខាតនៃសមាជិកព្រឹទ្ធសភា)រឺក៏ដោយដោយគណៈកម្មអចិន្ត្រៃយ៍ព្រឹទ្ធសភា។ រឿងទាំងនេះគឺអាស្រ័យលើបញ្ញត្តិនៃក្រមសីលធម៌ ដែលគេចង់បាន។ ប្រសិនបើក្រមសីលធម៌មានតំលៃដូចបទបញ្ជាផ្ទៃក្នុង គេចាំបាច់ឲ្យមានការអនុម័តដោយសំលេងភាគច្រើនដាច់ខាត (មាត្រាទី ១១៤ នៃរដ្ឋធម្មនុញ្ញ)។ ប្រសិនបើក្រមសីលធម៌មានបញ្ញត្តិពីទណ្ឌកម្មណាមួយក្នុងករណីមានការមិន គោរពនោះ យន្តការខាងលើគឺសមស្របបំផុត។ ម្យ៉ាងវិញទៀត ប្រសិនបើក្រមសីលធម៌មិនមាន ការចាប់បង្ខំរឺមានការចាប់បង្ខំតិចតួចហើយគ្រាន់តែជាឯកសារនាំផ្លូវឥរិយាបទប៉ុណ្ណោះ ដោយ មិនមានទណ្ឌកម្មនោះ ការអនុម័តដោយគណៈកម្មាធិការអចិន្ត្រៃយ៍គឺគ្រប់គ្រាន់ហើយ នេះបើ យោងទៅតាមសមត្ថកិច្ចរបស់ខ្លួនដែលទទួលស្គាល់ដោយមាត្រា១៤ នៃបទបញ្ជាផ្ទៃក្នុង[71]។ ក៏ប៉ុន្តែ ចំនុចដែលគួរតែកត់សំគាល់ នោះគឺគណៈកម្មការអចិន្ត្រៃយ៍ បច្ចុប្បន្ននេះពុំមាន សមាជិកណាមួយមកពីគណបក្សប្រឆាំងឡើយ។ ហេតុនេះហើយ ដើម្បីធានាឲ្យមានធម្មានុញ្ញភាព នឹង ការទទួលស្គាល់កាន់តែទូលំទូលាយ ដោយសមាជិកព្រឹទ្ធសភាទាំងអស់ នោះការអនុម័តដោយមតិភាគច្រើន នៅក្នុងការប្រជុំពេញអង្គព្រឹទ្ធសភានឹងផ្តល់អោយមានទំងន់ធ្ងន់ជាងមុន។

ការរៀបចំអោយមានក្រមសីលធម៌ គឺជាឱកាសក្នុងការកែតំរូវការធ្លាក់ចុះនូវដំណើរការ អនុវត្តការងាររបស់អង្គនីតិបញ្ញត្តិដែលសាធារណៈជនមាន។ នៅក្នុងសភាខ្លះកំហុសដែលបង្ក ឡើងដោយសមាជិកសភាមួយចំនួន គឺជាហេតុផលត្រូវបង្កើតឲ្យមានក្រមសីលធម៌មួយឡើង ចំណែកឯនៅសភាខ្លះទៀត ទុក្ខកង្វល់របស់ប្រជាជនជាទូទៅចំពោះស្តង់ដារការងារ និងឥរិយា បទរបស់អ្នកនយោបាយ[72]ជាមូលហេតុបង្កើតអោយមានក្រមសីលធម៌។ នៅបណ្តាប្រទេសមួយ ចំនួនទៀត ចំណុចចាប់ផ្តើមគិតគូរពីក្រមសីលធម៌គឺសមាជិកសភាយល់ដឹងពីនីតិវិធីដែលមាន ចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ប៉ុន្តែមិនដឹងពីឥរិយាបទណាសមស្របរឺមិនសមស្របក្នុងនាមជា

[71] បទបញ្ញត្តិចែងដូចតទៅ ៖ “គណៈកម្មាធិការអចិន្ត្រៃយ៍ នៃព្រឹទ្ធសភាគួរមានតួនាទីដូចតទៅ ៖ (ក) ធ្វើការដឹកនាំ គ្រប់គ្រង តាមដាន និង សំរេចចិត្ត នៅរាល់គ្រប់ ការងារ និង សកម្មភាពនៃព្រឹទ្ធសភា...”

[72] សៀវភៅក្បួន ទំព័រ ១៣។

សមាជិកសភាម្នាក់នោះទេ។ ចំណុចនេះកើតឡើងចំពោះប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យក្មេងខ្ចីដែលនៅក្នុងនោះ ស្តង់ដារសំរាប់ឥរិយាបទសភាមិនទាន់បង្កើតអោយមាននៅឡើយ។

ប្រភេទនៃ*«វិបត្តិ»* ដែលនាំអោយមានការពិភាក្សាគ្នាទាក់ទងនឹងវិសាលភាពនៃក្រមសីលធម៌ គឺថាតើក្រមនិយាយពីជំលោះផលប្រយោជន៍ រឺ មានគោលបំណងលើកកំពស់ការជឿជាក់របស់សាធារណៈជនចំពោះស្ថាប័ន រឺគួរចែងអំពីឥរិយាបទរបស់សមាជិកសភាក្នុងពេលប្រជុំពេញអង្គ? នៅក្នុងបរិបទកម្ពុជាឥរិយាបទមួយចំនួនរបស់សមាជិកព្រឹទ្ធសភា មានចែងរួចជាស្រេចទៅហើយនៅក្នុងបទបញ្ជាផ្ទៃក្នុង[73] ហើយចំណុចនេះមិនចាំបាច់ចែងនៅក្នុងក្រមសីលធម៌ទៀតទេ។ ជាជំនួសវិញក្រមសីលធម៌គួរមានចែងពីជំលោះផលប្រយោជន៍ គឺកំណត់យ៉ាង ណាបញ្ចៀសកុំឲ្យមានបញ្ហានេះដែលអាចនាំអោយកិត្យានុភាពរបស់សភានិងសមាជិកសភា កាន់តែប្រសើរឡើង។

## ២-ការព្រមព្រៀងគ្នាលើគោលការណ៍ទូទៅ

ជំហានបន្ទាប់តម្រូវឲ្យមានការព្រមព្រៀងគ្នាលើគោលការណ៍ទូទៅ ដែលអាចចាត់ទុកថាជាលក្ខខណ្ឌសំខាន់នៃក្រមសីលធម៌។ ការយល់ព្រមទៅលើគោលការណ៍ទូទៅមានលក្ខណៈ ងាយស្រួល ចំណែកឯការព្រមព្រៀងគ្នាលើទៅលើចំណុចលម្អិតអាចនឹងមានភាពលំបាកស្មុគស្មាញ។

ជាទូទៅ មានគោលការណ៍សក្តានុពលបីដែលអាចជាប្រភពនៅក្នុងការតាក់តែងក្រមសីលធម៌ ៖ ប្រព័ន្ធច្បាប់នៃប្រទេសនោះផ្ទាល់ (សំដៅទៅលើ រដ្ឋធម្មនុញ្ញ នឹងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា) យន្តការនៅក្នុងសភាផ្សេងៗទៀត និង លិខិតុបករណ៍អន្តរជាតិ ។

នៅក្នុងប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញ ក៏ដូចជាបទបញ្ជាផ្ទៃក្នុង ពុំបានផ្តល់នូវការណែនាំច្បាស់លាស់អំពីគោលការណ៍ទូទៅនៃក្រមសីលធម៌នោះឡើយ។ លិខិតបទដ្ឋាននៃសភាបរទេសដែលគេតែងតែយោងនោះគឺ គោលការណ៍ដែលអភិវឌ្ឍន៍ដោយគណៈកម្មាធិការស្តីពីស្តង់ដារនៅក្នុងជីវិតសាធារណៈនៅក្នុងប្រទេសអង់គ្លេសឆ្នាំ ១៩៩៥ ។ គោលការណ៍ទាំង៧ដាក់ចេញដោយគណៈកម្មាធិការនេះរួមមាន ៖ ភាពមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន បូរណភាព វត្ថុវិស័យភាព គណនេយ្យភាព ភាពបើកចំហ ភាពស្មោះត្រង់ នឹងភាពជាអ្នកដឹកនាំ[74] ។ ប្រភពអន្តរជាតិដ៏សំខាន់ដែលគួរតែយោងលើនោះគឺ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (ដែលប្រទេសកម្ពុជាជាភាគី) ។ មាត្រា ៨ នៃ អនុសញ្ញាអង្គការ សហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ តម្រូវអោយ រដ្ឋជាភាគីនីមួយៗគប្បីធ្វើការលើកកម្ពស់ បូរណភាព ភាពស្មោះត្រង់ និង

[73] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ជំពូកទី ១៣ ស្តីពី "វិន័យនៅក្នុងព្រឹទ្ធសភា" ឧទាហរណ៍ ការជេរប្រមាថសមាជិកព្រឹទ្ធសភាដូចគ្នាគួរតែដាក់ទណ្ឌកម្មដោយញត្តិបន្ទោស

[74] http://www.publications.parliament.uk/pa/cm201213/cmselect/cmstandards/724/72405.htm

ការទទួលខុសត្រូវនៅក្នុងចំណោមមន្ត្រីសាធារណៈ បើអាចគឺតាមរយៈក្រមសីលធម៌។ អង្គការជាសាកលនៃសមាជិកសភាតំណាងរាស្ត្រប្រឆាំងនឹងអំពើពុករលួយ **(GOPAC)** ក៏អាចចាត់ទុកថាជាតួអង្គដ៏សំខាន់ក្នុងវិស័យនេះផងដែរ ពីព្រោះជាអង្គការសំរាប់អនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយនេះ។ ដូចនេះហើយ អង្គការជាសាកលនៃសមាជិកសភាតំណាងរាស្ត្រប្រឆាំងនឹងអំពើពុករលួយ ក៏អាចជាប្រភពធនធានមួយដ៏មានសារៈប្រយោជន៍សម្រាប់ព្រឹទ្ធសភាក្នុងការអំពាវនាវសុំជំនួយ ក្នុងការអភិវឌ្ឍន៍ក្រមសីលធម៌ ។

## ៣- ការបង្កើតវិធានដែលមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ

បន្ទាប់ពីគោលការណ៍ទូទៅត្រូវបានបង្កើត យើងអាចបង្កើតនូវវិធានដែលមានលក្ខណៈលម្អិត។ វិធានទាំងនេះនឹងកំណត់បញ្ហាថាអ្វីជាជម្លោះផលប្រយោជន៍។ បន្ថែមពីនេះទៀតវិធានទាំងនេះនឹងផ្តល់តម្លាភាពក្នុងគោលបំណងកាត់បន្ថយហានិភ័យ នៃការកើតមាននូវជម្លោះផលប្រយោជន៍ទាំងនោះ។ ជាចុងក្រោយវិធានទាំងនេះបញ្ជាក់ពីដែនកំណត់នៃសកម្មភាព ដែលជាចំណោទបញ្ហារបស់អ្នកនយោបាយក្នុងរឿងរ៉ាវដែលមានបញ្ហាដូចជាការទទួលអំណោយដែលមានចំនួនទឹកប្រាក់ហួសពីការកំណត់ជាដើម។

ក្នុងការព្រមព្រៀងទៅលើគោលការណ៍ទូទៅដូចដែលបានកំណត់ក្នុងជំហានទីពីរខាងលើ សមាជិកសភាព្រមព្រៀងលើគោលការណ៍ទូទៅនៃក្រមសីលធម៌មានចំនួនកាន់តែច្រើន គឺកាន់តែល្អ។ បន្ទាប់មកទៀតគេអាចប្រគល់ភារកិច្ចទៅដល់ក្រុមតូចៗដើម្បីរៀបចំវិធានលម្អិតដែលជាជំហានទី៣។ ជម្រើសជាទូទៅក្នុងកិច្ចការនេះ គឺការបង្កើតគណៈកម្មការចំពោះកិច្ចមួយដែលមានសមាជិកពីគណបក្សទាំងអស់ដែលមានតំណាងក្នុងសភាដោយផ្អែកលើចំនួនសមាជិករបស់គណបក្សទាំងនោះនៅក្នុងសភាពេញអង្គ។ ក្នុងករណីណាក៏ដោយដើម្បីទទួលបាន "ការយល់ព្រម" ពីគណបក្សប្រឆាំង គេត្រូវប្រាកដថាគណបក្សប្រឆាំងមានតំណាងគ្រប់គ្រាន់ក្នុងគណកម្មការចំពោះកិច្ចនេះ។ ដូចគ្នាទៅនឹងប្រធានបទដទៃទៀតផងដែរ គណៈកម្មការនេះគួរទទួលយកយោបល់ជំនាញផ្សេងៗពីខាងក្រៅ។

ជាទូទៅ ជម្លោះផលប្រយោជន៍តែងតែកើតមានចំពោះអ្នកនយោបាយហើយ ជម្លោះនេះអាចនឹងឈានទៅដល់តវិយាបទអសីលធម៌ខ្លះ។ ជម្លោះផលប្រយោជន៍នេះកើតឡើង នៅពេលដែលផលប្រយោជន៍ឯកជនរបស់សមាជិកសភាម្នាក់មានជម្លោះជាមួយនឹងផលប្រយោជន៍សាធារណៈដែលសមាជិករូបនោះមានកាតព្វកិច្ចបំពេញ។ ករណីនេះកើតឡើង នៅពេលដែល

សមាជិកសភាប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីទទួលបានផលប្រយោជន៍ឯកជនរបស់ខ្លួន។ ក្រមសីលធម៌ត្រូវបញ្ជាក់ពីឧទាហរណ៍នៃជម្លោះជាក់ស្តែងដែលអាចកើតមាន។ ឧទាហរណ៍ដូចជា សមាជិកសភាមួយរូបបោះឆ្នោតគាំទ្រគម្រោងដែលក្រុមហ៊ុនរបស់គាត់កំពុងតែដេញថ្លៃ។

ការបង្ហាញជាសាធារណៈ និងតម្លាភាពមិនអាចដោះស្រាយ រឺបញ្ចប់ជម្លោះដោយស្វ័យប្រវត្តិនោះទេ ប៉ុន្តែអាចជួយក្នុងការកំណត់អត្តសញ្ញាណនៃការកកើតមានឡើងនូវជម្លោះផលប្រយោជន៍។ ដូចនេះ ជាធម្មតា រាល់ក្រមសីលធម៌ទាំងអស់តម្រូវឲ្យសមាជិកសភាផ្តល់ព័ត៌មានជាក់ស្តែងផ្ទាល់ខ្លួន(ជាសេចក្តីប្រកាស) ចំពោះអ្នកចុះបញ្ជី រឺស្ថាប័នដែលត្រួតពិនិត្យក្រមសីលធម៌ ដូចនេះផលប្រយោជន៍ឯកជនរបស់សមាជិកសភាអាចលេចចេញជារូបរាងច្បាស់លាស់។ ដើម្បីឲ្យកាន់តែមានប្រសិទ្ធិភាពបន្ថែមទៀត ដូចដែលស្ថានភាពរបស់មាជិកសភាអាចផ្លាស់ប្តូរ សេចក្តីប្រកាសនេះគួរតែត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់។ ក្នុងកាលៈទេសៈ មួយចំនួន ដើម្បីបញ្ចៀសកុំអោយមានការបំពានលើក្រមវិធានផ្សេងៗ មិនត្រឹមតែសមាជិកសភាប៉ុណ្ណោះទេដែលត្រូវប្រកាស ប៉ុន្តែថែមទាំងសាច់ញាតិរបស់សមាជិកទាំងនោះទៀតផង ដែលតម្រូវឲ្យប្រកាសពីផលប្រយោជន៍របស់ខ្លួន។ ប៉ុន្តែកង្វល់លើជីវិតឯកជនរបស់ពួកគាត់អាចត្រូវបានដោះស្រាយដោយត្រូវថ្លឹងថ្លែងលើកម្រិតដែលសាធារណៈជន អាចទទួលបានពត៌មានពីក្រុមគ្រួសាររបស់សមាជិកសភា និងភាពបើកចំហជាសាធារណៈនូវពត៌មានទាំងអស់នោះ។

អ្នកចុះបញ្ជីតែងតែចុះនូវពត៌មានទាក់ទងនឹងទ្រព្យសម្បត្តិរបស់សមាជិកសភាដូចជា អចលនៈទ្រព្យ ភាគហ៊ុន។ល។ លើសពីនេះទៀត អ្នកចុះបញ្ជីអាចបញ្ចូលចំណុចមួយចំនួនទៀត ដូចជា៖

- ប្រាក់ចំណូលដែលសមាជិកសភាទទួលបានទទួលបានក្រៅពីសភា
- ការទទួលខុសត្រូវផ្សេងៗរបស់សមាជិកសភា ឧទាហរណ៍លើបំណុល
- អំណោយដែលសមាជិកសភាទទួល (ការកំណត់ចំនួនទឹកប្រាក់លើអំណោយដែលអាចទទួលបាន) និងផលប្រយោជន៍ស្រដៀងគ្នានេះ (ឧទាហរណ៍ ការធ្វើដំណើរដោយមិនចាំបាច់ចេញសោហ៊ុយ ការធ្វើដំណើរបង់ថវិការដោយគណបក្ស មិនមែនដោយសភា)[75]។

ពេលដែលគេរកឃើញជម្លោះផលប្រយោជន៍ គេត្រូវអនុវត្តការវិធានការណ៍ដែលជាផលវិបាកផ្សេងៗដែលបានកំណត់យ៉ាងច្បាស់ក្នុងក្រមសីលធម៌ (ឧទាហរណ៍ មិនឲ្យសមាជិកសភាចូលរួមការពិភាក្សាដេញដោល និងការបោះឆ្នោត)។ លើសពីនេះទៀត នៅក្នុងសភាមួយចំនួន

[75] សូមពិនិត្យមើល កូនសៀវភៅ ទំព័រ ២៨ និង **Stapenhurst/Pelizzop.9/10)**

សមាជិកសភាត្រូវបានហាមឃាត់មិនឲ្យប្រើ រឺក្នុងករណីខ្លះទទួលយក ការងារ រឺការចាត់តាំងក្រៅពីសមត្ថកិច្ចរបស់សភា។ ទាក់ទងនឹងបញ្ហានេះ មាត្រា ១០៣ នៃរដ្ឋធម្មនុញ្ញកម្ពុជាកំណត់នូវការហាមឃាត់មួយចំនួន[76]។

## ៩- យន្តការអនុវត្ត

ជំហានបន្ទាប់ គឺការកំណត់បទប្បញ្ញត្តិដែលសំរាប់អនុវត្តក្រមសីលធម៌។នៅក្នុងប្រទេសផ្សេង មានគំរូចំនួនបីផ្សេងៗគ្នាដែលគេបានបង្កើតឡើងដើម្បីអនុវត្តអនុវត្ត ក្រមសីលធម៌។ គំរូមួយដែលកម្របំផុតគឺការត្រួតពិនិត្យដោយស្ថាប័នខាងក្រៅ ដែលក្រៅពីសភា។ ដោយសារក្នុងប្រទេសភាគច្រើន (រួមទាំងប្រទេសកម្ពុជា) គំរូរបៀបនេះអាចនឹងជ្រៀតជ្រែកលើគោលការណ៍ឯករាជ្យរបស់សភាដែលមានចែងក្នុងរដ្ឋ ធម្មនុញ្ញ។ ចំណែកឯគំរូពីរផ្សេងទៀតនោះត្រូវបានប្រើប្រាស់ជាទូទៅយ៉ាងទូលំទូលាយ។ គំរូទីមួយគឺផ្អែកទៅលើការត្រួតពិនិត្យផ្ទៃក្នុងដែលអាចស្តែងឡើងតាមរយៈការបង្កើតគណៈ កម្មការធិការសភាមួយ។ មួយទៀតនោះគឺគំរូកូនកាត់គឺស្ថាប័នឯករាជ្យខាងក្រៅសភាជាអ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេត ការរំលោភបំពានក្រមសីលធម៌ ចំណែកឯការដាក់ទណ្ឌកម្មត្រូវ សម្រេចដោយគណៈកម្មាធិការរបស់សភាខ្លួនឯង។ ផលវិបាកនៃដំណោះស្រាយដែលមានតែគណៈកម្មាការសភានោះគឺថាយន្តការនេះអាចក្លាយជារឿងនយោបាយ និងអាចប្រឈមនឹងការបាត់បង់ការទុកចិត្តពីសាធារណៈជន។បញ្ហានេះអាចត្រូវបានដោះស្រាយតាមរយៈគំរូកូនកាត់ដែលអាចជៀសវាងកុំអោយសភាជាអ្នកស៊ើបអង្កេត ដែលនេះមិនមែនជាតួនាទីមួយរបស់គាត់នោះទេ។ សំណួរគន្លឹះមួយទៀតនៅក្នុងប្រព័ន្ធណាមួយក៏ដោយគឺថាតើគេចាប់ផ្តើមការស៊ើបអង្កេតយ៉ាងដូចម្តេច-រឺក្នុងន័យមួយទៀត តើអ្នកណាមានសិទ្ធិប្តឹង និងចាប់ផ្តើមនីតិវិធីស៊ើបអង្កេត- សមាជិកសភា សាធារណៈជន? បញ្ហានេះគួរតែត្រូវបានពិចារណាដោយប្រុងប្រយ័ត្ន នៅពេលធ្វើការតាក់តែងក្រមសីលធម៌ក្នុងន័យធានាថាក្រមនេះមានប្រសិទ្ធិភាពនិងអាចអនុវត្តទៅបាន។

ទាក់ទងនៅនឹងទណ្ឌកម្មដែលអាចមាន ប្រទេសជាច្រើនអនុវត្តទណ្ឌកម្ម ស្រដៀងគ្នាទៅនឹងទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៧៦ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា[77]។ ព្រឹទ្ធសភាគួរពិនិត្យមើលចំណុចនេះដើម្បីបានជាគំនិតយោបល់ក្នុងការបង្កើតក្រមសីលធម៌។

[76] មាត្រា ១០៣ចែងថា៖ ‘សមាជិកព្រឹទ្ធសភាមួយរូបមិនអាចកាន់មុខងារសាធារណៈណាមួយបានោះទេ ជាសមាជិករដ្ឋសភា ឬជាសមាជិកនៃស្ថាប័នដទៃទៀតដែលចែងក្នុងរដ្ឋធម្មនុញ្ញ’។

## ៥- ការអនុវត្ត

ដើម្បីអោយក្រមសីលធម៌អាចអនុវត្តបាន សំខាន់ណាស់ត្រូវមាន ការគាំទ្រពីថ្នាក់ដឹកនាំសភា និងគណបក្សនយោបាយដែលមានអសនៈក្នុងសភា។ នៅពេលដែលមាន“ការយល់ព្រម” លើក្រម ហើយក្រមនេះត្រូវបានបង្កើត គេនឹងឈានដល់ការរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗ ដើម្បីជម្រាបសមាជិកសភាពីវិធីសាស្រ្តអនុវត្តក្រមសីលធម៌នេះ នីតិវិធីដែលមានចែងនៅក្នុងក្រម នៅពេលដែលមានការរំលោភបំពានលើក្រមសីលធម៌។ ចំណុចនេះគួរតែត្រូវបានបញ្ចូលក្នុងកម្មវិធីពន្យល់ណែនាំដល់ទាំងសមាជិកព្រឹទ្ធសភាថ្មី និងសមាជិកព្រឹទ្ធសភាចាស់។ លើសពីនេះទៀត កូនសៀវភៅអាចត្រូវបានបង្កើតឡើងដើម្បីផ្តល់ពត៌មានពាក់ព័ន្ធ នឹងការណែនាំ លើវិធីសាស្រ្តអនុវត្តក្រមសីលធម៌។ ជាចុងក្រោយ នៅក្នុងសភាដទៃទៀត កត្តាជោគជ័យនោះគឺ ការបង្កើតការិយាល័យពិសេសមួយដែលជាស្ថាប័នអចិន្ត្រៃយ៍ដើម្បីធ្វើការណែនាំ និងផ្តល់យោបល់ដល់សមាជិកសភាទាក់ទងនឹងសំណួរស្តីពីក្រមសីលធម៌។

## ៦- សេចក្តីសន្និដ្ឋាន

តាមរយៈការបង្ហាញខាងលើ យើងអាចធ្វើការសន្និដ្ឋានបានថាដំណើរការនៃការបង្កើត និងអនុវត្តក្រមសីលធម៌មួយគឺទាក់ទងទៅនឹងកត្តានយោបាយ។ ទ្រង់ទ្រាយនៃក្រមនេះនឹងត្រូវកំណត់ដោយលក្ខខណ្ឌនយោបាយ និងតម្លៃវប្បធម៌របស់ស្ថាប័នក៏ដូចជាឥរិយាបថរបស់ឥស្សរៈជនសំខាន់ៗក្នុងសភាផងដែរ[78]។ ដំណើរការនៃការបង្កើតក្រមសីលធម៌ គឺមាន សារៈសំខាន់ដូចទៅនឹងក្រមសីលធម៌នោះដែរ។ ដំណើរការនេះអាចទទួលបានជោគជ័យប្រសិនបើសមាជិកសភាចាត់ទុកថាខ្លួនជាម្ចាស់ទាំងលើដំណើរការ និងលទ្ធផលចុងក្រោយ។ ដូចនេះជាការសំខាន់ណាស់ដែលសមាជិកសភាមានទស្សនៈរួមគ្នាលើតំលៃសីលធម៌ និង ព្រមព្រៀងគ្នាជាមូលដ្ឋាន

[77] ទណ្ឌកម្មចាប់ផ្តើមពី (ក)ចេញសេចក្តីព្រមានពាក់ព័ន្ធនឹងសកម្មភាពមួយ (ខ) ចេញសេចក្តីព្រមានដែលត្រូវបានកត់ត្រាក្នុងកំណត់ហេតុ (គ) ចេញញត្តិបន្ទោសជាលាយលក្ខអក្ស (ឃ)ចេញញត្តិបន្ទោសជាលាយលក្ខអក្សរ និងបញ្ជាឲ្យរជាបណ្តោះអាសន្នមិនឲ្យចូលរួមកិច្ចប្រជុំ។

[78] កូនសៀវភៅ ទំព័រទី ៤១

លើបញ្ហាដែលពាក់ព័ន្ធជាមួយនឹងការរក្សានូវតម្លៃទាំងនោះ  ព្រមទាំងលើវិធីសាស្រ្តក្នុងការជំនះលើបញ្ហាទាំងអស់នោះផងដែរ[79]។

## VI- សេចក្តីសន្និដ្ឋាន

ឯកសារនេះបានកត់សម្គាល់នូវចំណុចពាក់ព័ន្ធថ្មីរបស់ក្រមសីលធម៌ជាមួយនឹងនយោបាយសភា។  ជាក់ស្តែង  ក្នុងបណ្តាសភាចំនួនបីដែលបានលើកឡើងខាងលើមានតែសភាចំនួនពីរប៉ុណ្ណោះដែល ដាក់ឲ្យប្រើប្រាស់ក្រមសីលធម៌។ ជាទូទៅ ក្រមសីលធម៌អាចមានទម្រង់ពីរបែបៈ លក្ខណៈបង្ខំ  ឲ្យអនុវត្តដូចនៅប្រទេសកាណាដា  និងលក្ខណៈជម្រុញទឹកចិត្តឲ្យអនុវត្តដូចនៅប្រទេសបារាំង រឺ ដូចដែលកំពុងស្នើឲ្យអនុវត្តនៅប្រទេសអូស្រ្តាលី។ ដូចគ្នាដែរ ដូចដែលបានបកស្រាយក្នុងជំពូក ទី៥ នៃផ្នែកទី៨ការអនុវត្តក្រមសីលធម៌អាចត្រូវប្រគល់ទៅឲ្យអាជ្ញាធរដែលមានសមត្ថកិច្ចឯករាជ្យមួយរបស់សភា ឲ្យទៅសភាខ្លួនឯងរឺឲ្យទៅអង្គការទាំងពីរតាមទម្រង់កូនកាត់។ ប៉ុន្តែទោះជាយ៉ាងនេះក្តី  ប្រសិនបើមិនគិតអំពីទម្រង់ជាក់លាក់ទេ  ជារួមក្រមសីលធម៌សភាមានទិសដៅពីរដែល ដូចគ្នាៈ ទីមួយ ការលើកម្ពស់ជំនឿទុកចិត្តរបស់សាធារណៈជូនលើអ្នកតំណាងដែលជាប់ឆ្នោត  តាមរយៈការធ្វើឲ្យមានតម្លាភាពខ្ពស់នៃផលប្រយោជន៍ហិរញ្ញវត្ថុរបស់សមាជិកសភា  និងទីពីរការជួយសមាជិកសភាតាមរយៈការផ្តល់ឲ្យពួកគេនូវក្រមសីលធម៌មួយដែលងាយស្រួលអនុវត្ត ដែលអនុញ្ញាតឲ្យពួកគេអាចផ្ទៀងផ្ទាត់សកម្មភាពរបស់ពួកគេបាន។ ដោយហេតុថាអំណាចរបស់តុលាការ  និងសភាត្រូវបានបែងចែកដាច់ពីគ្នា  ធ្វើឲ្យភាពជោគជ័យនៃការអនុវត្តក្រមសីលធម៌ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការគាំទ្រដោយស្ម័គចិត្តរបស់សមាជិកសភា។  តាមលក្ខខណ្ឌនេះ  ផលវិបាកដែលអាចមានសម្រាប់ក្រមសីលធម៌ដែលកំពុងស្ថិតក្នុងការពិចារណារបស់កម្ពុជាគឺ ការធ្វើឲ្យប្រាកដថាការកសាងក្រមនេះត្រូវបានធ្វើដោយឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយនូវពហុទស្សនៈនយោបាយ។

## គន្ថនិទេស

Brien, A. 1998.*A Code of Conduct for Parliamentarians.* Department of the Parliamentary Library, Canberra.

[79] **Stapenhurst/Pelizzo** ទំព័រទី១៦/១៧

*Code de conduite et régime parlementaire en France*, Available from: http://recueil.apf-francophonie.org/spip.php?article16

Dawson, M. 2013.*The Conflict of Interest Act: Five-Year Review: Submission to the Standing Committee on Access to Information, Privacy and Ethics*. Office of the Interest and Ethics Commissioner, Ottawa.

Deschamps, M. *Quand la déontologie fait son entrée officielle à l'Assemblée nationale...des questions juridiques et institutionnelles surgissent*. Available from : http://hp.gredeg.cnrs.fr/Marc_Deschamps/Pdf/AN.pdf

Fournier, J. 2009. 'Emergence of a Distinctive Canadian Model of Parliamentary Ethics'. *Journal of Parliamentary and Political Law*, Vol. 2 No. 3 May 2009, Ottawa.

Fournier, J. 2009. 'Recent Developments in Canadian Parliamentary Ethics'. *Canadian Parliamentary Review,* Summer 2009, Ottawa.

House of Representatives Standing Committee of Privileges and Members' Interests.2011.*Draft Code of Conduct for Members of Parliament Discussion Paper.*

King Prajadhipok's Institute, *Codes of conduct for parliamentarians*, February 2008.

McKeown. D. 2012. *Codes of Conduct in Australian and Selected Overseas Parliaments.* Department of Parliamentary Services. Canberra.

Office of the Conflict of Interest and Ethics Commissioner. 2013. *Independence of the Commissioner*. Ottawa. Accessed 14/10/2013 from: http://ciec-ccie.gc.ca/Default.aspx?pid=75&lang=en

Office of the Senate Ethics Officer. 2013. *About the Office*. Ottawa. Accessed 14/10/2013 from: http://sen.parl.gc.ca/seo-cse/eng/Office-e.html

Power, G*. Handbook on Parliamentary Ethics and Conduct – A Guide for Parliamentarians*, 2010, Cited as 'Handbook', accessible at http://www.wfd.org/upload/docs/political_guidebook_20100630.pdf

Privy Council Office. 2011. *Accountable Government: A Guide for Ministers and Ministers of State,* Ottawa.

Stapenhurst, R. Pelizzo, R. *Legislative Ethics and Codes of Conduct*, 2004, cited as Stapenhurst/Pelizzo, accessible at http://siteresources.worldbank.org/EXTPARLIAMENTARIANS/Resources/Legislative_Ethics_and_Codes_of_Conduct.pdf